ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ឥទ្ធិពលនៃពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា

ជំនាញៈ សវនកម្ម

រៀបរៀងដោយ៖ ឈួរ ស៊ីវជួ
អត្តលេខៈ MA020/002

ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

ក្រសួងអប់រំ យុវជន និងកីឡា
MINISTRY OF EDUCATION YOUTH AND SPORTS
សាកលវិទ្យាល័យវ៉ាន់ដា
VANDA UNIVERSITY

# របាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា
# ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់

# ឥទ្ធិពលនៃពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា

ជំនាញ: សវនកម្ម
សាស្ត្រាចារ្យណែនាំ ៖ បណ្ឌិត កង ឱម
បេក្ខបណ្ឌិត យ៉េម សុខហៀក
ឆ្នាំសិក្សា ៖ ឆ្នាំ២០២២ - ២០២៤

**គណៈកម្មការត្រួតពិនិត្យរបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សា**
**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី២១**
**ប្រធានបទ៖ ឥទ្ធិពលនៃពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា**

| | |
|---|---|
| លោកគ្រូណែនាំ | សាស្ត្រាចារ្យណែនាំ |
| បេក្ខបណ្ឌិត យ៉ែម សុខហៀក | បណ្ឌិត កង ឌិម |
| សាកលវិទ្យាធិការរងអចិន្ត្រៃយ៍ | នាយកមជ្ឈមណ្ឌលស្រាវជ្រាវ |
| បណ្ឌិត ហ៊ូ គុជគន្ធលីនណា | បណ្ឌិត សេង សំអឿន |

**សាកលវិទ្យាធិការ**

**បណ្ឌិត ហេង វ៉ាន់ដា**

# ឧទ្ទិសស្នាដៃ

នាងខ្ញុំឈ្មោះ **ឈួរ ស៊ីវជូ** ជាបេក្ខជនសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាញ **សវនកម្ម** ជំនាន់ទី២០ នៃសាកលវិទ្យាល័យវ៉ាន់ដា។

សូមឧទ្ទិសស្នាដៃ នៃការស្រាវជ្រាវនេះថ្វាយចំពោះព្រះវិញ្ញាណក្ខន្ធវីរព្រះមហាក្សត្រខ្មែរ គ្រប់សម័យកាល ដែលព្រះអង្គបានធ្វើព្រះរាជបូជនីយកិច្ច ដើម្បីបុព្វហេតុជាតិនិងមាតុភូមិ។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធមេដឹកនាំខ្មែរគ្រប់សម័យកាល ដែលបានធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីបុព្វហេតុជាតិ ប្រជាជន និងទឹកដី។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះលោកគ្រូ អ្នកគ្រូ ដែលបានចំណាយពេលវេលា ដ៏មានតម្លៃមកបង្ហាត់បង្រៀនដល់រូបខ្ញុំ ក្នុងការសិក្សានៅគ្រប់កម្រិតថ្នាក់ និងការសរសេរនិក្ខេបបទនេះ។ សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះអ្នកសិក្សាគ្រប់ជំនាន់ ដែលបានចំណាយពេល វេលា សម្ភារៈ និងទ្រព្យធន ក្នុងការចងក្រងឯកសារនានា ទុកសម្រាប់កូនចៅជំនាន់ក្រោយ បានសិក្សា រៀនសូត។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះវិញ្ញាណក្ខន្ធយុទ្ធជន យុទ្ធនារី កុលបុត្រ កុលធីតា និងជនរួមជាតិខ្មែរគ្រប់រូប ពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបានធ្វើពលិកម្ម នៅគ្រប់សម័យកាល ដើម្បីបុព្វហេតុជាតិ មាតុភូមិ និងប្រជាពលរដ្ឋរបស់យើងទាំងអស់គ្នា។

សូមឧទ្ទិសស្នាដៃនៃការស្រាវជ្រាវនេះ ជូនចំពោះពុទ្ធបរិស័ទខ្មែរ និងជនស្នេហាជាតិទាំងអស់ ដែលបាន លះបង់ ធ្វើពលិកម្មគ្រប់បែបយ៉ាងដើម្បីបុព្វហេតុជាតិមាតុភូមិ។

សូមឱ្យមាតុភូមិកម្ពុជា ស្ថិតនៅគង់វង្ស មានភាពរុងរឿងសម្បូរសប្បាយ មានភាពថ្លៃថ្នូរ និង ថ្កុំថ្កើងតរៀងទៅ

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញសវនកម្ម នៅវិទ្យាស្ថានវ៉ាន់ដា អស់រយៈពេល ២ឆ្នាំរួចមក នាងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន ដែលពាក់ព័ន្ធនឹងមុខវិជ្ជាសវនកម្ម គណនេយ្យ ពន្ធដា ជាពិសេសយល់ច្បាស់ថាជំនាញសវនកម្ម គឺជាជំនាញមួយដ៏មានសារៈសំខាន់ សម្រាប់តម្រូវការស្ថាប័នទាំងអស់ មិនថាស្ថាប័នរដ្ឋ ស្ថាប័នឯកជន ឬអង្គការក្រៅរដ្ឋាភិបាលឡើយ។ ក្នុងនោះផងដែរដើម្បីឱ្យការសិក្សារបស់និស្សិតកាន់តែស៊ីជម្រៅលើជំនាញរបស់ខ្លួន វិទ្យាស្ថានក៏បានបញ្ចូលមុខវិជ្ជាជាច្រើន ដែលពាក់ព័ន្ធទៅនឹងកម្មវិធីសិក្សាទៅតាមកម្រិត ពីឆ្នាំទីមួយ រហូតដល់ឆ្នាំទីពីរដែលត្រូវបញ្ចប់ការសិក្សា។

គ្រប់មុខវិជ្ជាទាំងអស់ សុទ្ធតែជាយានសម្រាប់ឱ្យនិស្សិតយកទៅប្រើប្រាស់ នៅក្នុងវិស័យការងារបាន ជាពិសេសនោះ គឺមុខវិជ្ជាគណនេយ្យដែលស្ថាប័នត្រូវឱ្យបុគ្គលិកពាក់ព័ន្ធត្រូវមានចំណេះដឹង ដើម្បីរៀបចំ និងកាន់កាប់បញ្ជីគណនេយ្យឱ្យបានត្រឹមត្រូវ ស្របទៅតាមការណែនាំរបស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីជៀសវាងនូវបញ្ហាផ្សេងៗដែលអាចកើតមានឡើង និងធ្វើឱ្យមានការរាំងស្ទះដល់ដំណើរការអាជីវកម្មទៅថ្ងៃក្រោយ។ ដោយនាងខ្ញុំយល់ថាចំណេះដឹងខាងពន្ធដារ ជាចំណេះដឹងបន្ថែមមួយទៀតដ៏មានសារៈសំខាន់ សម្រាប់សវនករទាំងអស់ធ្វើការសិក្សាស្វែងយល់ និងស្របពេលដែលនាងខ្ញុំមានឱកាសបានសរសេររបាយការណ៍ស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផងនោះទើបនាងខ្ញុំសម្រេចចិត្ត ជ្រើសរើសនូវប្រធានបទមួយស្តីពី **«ឥទ្ធិពលនៃពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា.»** យកមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជារបាយការណ៍ក្នុងគោលបំណងឱ្យអ្នកអាន និងអ្នកស្រាវជ្រាវក្រោយៗទៀតឱ្យយល់កាន់តែច្បាស់ពីពន្ធដារ។ នាងខ្ញុំសង្ឃឹមថា ការរៀបចំរបាយការណ៍ស្រាវជ្រាវនេះ នឹងបានចូលរួមចំណែកក្នុងការស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ព្រមទាំងអ្នកដទៃទៀត ដែលមានបំណងលើការសិក្សាពីជំនាញគណនេយ្យ។

យើងខ្ញុំរង់ចាំទទួលការរិះគន់ពីសំណាក់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ មិត្តរួមជំនាន់ និងប្អូនៗជំនាន់ក្រោយ រាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនានូវពាក្យពេចន៍ វគ្គ ឃ្លា វេយ្យាករណ៍ អក្ខរក្រម ដើម្បីជួយកែលំអរឱ្យសៀវភៅនេះកាន់តែល្អ និងមានភាពសុក្រិត។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់មិត្តអ្នកអាន អ្នកស្រាវជ្រាវ លោកគ្រូ សាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ ទទួលបាននូវពរទាំងឡាយបួនសម្បត្តិបី អរិយទ្រព្យប្រាំពីរ និងមានសេក្តីសុខ សំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យនូវគោលបំណងដែលប៉ងគ្រប់ៗគ្នាកុំបីខានឡើយ។

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ជំនាន់ទី២០ ជំនាញសវនកម្មនៃវិទ្យាស្ថាន វ៉ាន់ដា។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

លោកឪពុក និងអ្នកម្តាយដែលបានផ្តល់កំណើត ហើយខិតខំបីបាច់ថែរក្សាកូន ព្រមទាំងផ្គត់ផ្គង់ដល់កូនសព្វបែបយ៉ាង ខិតខំលើកទឹកចិត្តកូនក្នុងការសិក្សា តាំងពីកូនចូលរៀនដំបូងរហូតមកដល់ពេលនេះ និងបានបង្រៀនកូនឱ្យចេះស្នេហាជាតិមាតុភូមិកម្ពុជា។

នាយក គណៈគ្រប់គ្រង បុគ្គលិក សាស្ត្រាចារ្យនៃវិទ្យាស្ថាន វ៉ាន់ដា ដែលជានិច្ចកាលតែងតែផ្តល់នូវការលើកទឹកចិត្ត អនុគ្រោះដល់នាងខ្ញុំរហូត ធ្វើឱ្យការសិក្សាបានបញ្ចប់ និងទទួលបានជោគជ័យគួរជាទីមោទនៈ។

ជាពិសេសសាស្ត្រាចារ្យ **បណ្ឌិត ភេង ឱម** និងសាស្ត្រាចារ្យ **យ៉េម សុខហៀក** ដែលលោកបានឆ្លៀតពេលវេលាដ៏មានតម្លៃ ដើម្បីជួយណែនាំដល់ការសរសេររបាយការណ៍របស់នាងខ្ញុំឱ្យរឹតតែមានភាពល្អប្រសើរ។

ជាទីបញ្ចប់នាងខ្ញុំ សូមលើកដៃសំពះបួងសួងដល់គុណព្រះរតនត្រ័យ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយបីបាច់ថែរក្សាដល់លោកអ្នកមានគុណខាងលើឱ្យជួបតែសេចក្តីសុខគ្រប់ប្រការកុំបីអាក់ខានឡើយ។

សូមគោរពជូនពរដល់គុណូបការជនទាំងអស់ សូមជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ ដ៏មហាប្រសើរគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អំណះអំណាង

នាងខ្ញុំសូមធានាអះអាង និងទទួលខុសត្រូវលើខ្លឹមសារនៅក្នុងរបាយការណ៍ស្រាវជ្រាវនេះថា របាយការណ៍ស្រាវជ្រាវនេះ គឺជាស្នាដៃស្រាវជ្រាវផ្ទាល់របស់នាងខ្ញុំ ដោយគ្មានពាក់ព័ន្ធជាមួយសារណា ឬរបាយការណ៍ស្រាវជ្រាវរបស់អ្នកផ្សេងឡើយ។ ចំពោះទិន្នន័យលទ្ធផលនៃការស្រាវជ្រាវដែលមានក្នុងរបាយការណ៍ស្រាវជ្រាវនេះ គឺថ្មីហើយក៏មិនទាន់មានជនណាម្នាក់យកទៅប្រើប្រាស់នៅក្នុងសារណា ឬ របាយការណ៍ស្រាវជ្រាវរបស់គេឡើយ។

ភ្នំពេញ ថ្ងៃទី..........ខែ............ឆ្នាំ២០២.......

**ហត្ថលេខា**

ថ្ងៃ.................ខែ................ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦....

ភ្នំពេញ ថ្ងៃទី..........ខែ...........ឆ្នាំ២០២....

**គ្រូណែនាំ**

# សេចក្តីសង្ខេបនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវនេះគឺដើម្បីវិភាគឥទ្ធិពលនៃពន្ធផ្ទាល់( Direct-tax )និងពន្ធប្រយោល ( Indirect-tax )ទៅលើសេដ្ឋកិច្ច។ ទិន្នន័យដែលយកមកសិក្សាស្រាវជ្រាវគឺអនុវត្តចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ ២០២០។ ការស្រាវជ្រាវនេះប្រើវិធីសាស្ត្រ Multiple Linear Regression សម្រាប់ធ្វើការប៉ាន់ស្មានអំពីទំនាក់ទំនង រវាងអថេរមិនឯករាជ្យ និងអថេរឯករាជ្យ ដែលជះឥទ្ធិពលលើកំណើនសេដ្ឋកិច្ច។ ការសិក្សាស្រាវជ្រាវនេះបានប្រើ Classical Assumption Test ដូចជា Normality Test , Multicollinearity Test និង Autocorrelation Testជាដើម ដើម្បីបង្ហាញពីភាពត្រឹមត្រូវនៅក្នុងការសិក្សា Regression Model ។

លទ្ធផលនៃការប្រើប្រាស់ F-Test បង្ហាញថា អថេរឯករាជ្យទាំង៣នេះ មានឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចដែលតម្លៃF=១២៣០.៤២៤ មានកម្រិតសំខាន់ 0.000%។ ចំពោះលទ្ធផលដែលទទួលបានពីការប្រើប្រាស់តាម T-Test បានបង្ហាញឲ្យឃើញថា អថេរឯករាជ្យទាំងអស់ ដែលលើកយកមកសិក្សាវិភាគនេះ មានឥទ្ធិពលលើអថេរមិនឯករាជ្យ នៃកំណើនសេដ្ឋកិច្ច ព្រោះ DT, IDT, និង TIT មានកម្រិតសំខាន់ស្មើ0.000,0.000 និង0.000ឥទ្ធិពលនៃអថេរឯករាជ្យ Direct tax ,Indirect tax, និង Tax on International Trade អថេរមិនឯករាជ្យលើកំណើនសេដ្ឋកិច្ច ដែលអាចពន្យល់ប្រាប់ថា R Square =៩៨.៩%

# Research Summary

The purpose of this research is to analyze the effects of direct and indirect taxes on the economy. The data used in the study are from 2010 to 2020. This research uses the Multiple Linear Regression method to estimate the relationship between dependent variables and independent variables that affect economic growth. This research uses Classical Assumption Test such as Normality Test, Multicollinearity Test and Autocorrelation Test to show the validity of the Regression Model study. The results of using F-Test show that these three independent variables have a significant effect on economic growth with the value of F=1230.424 with a significance level of 0.000%. The results obtained from the use of the T-Test showed that all independent variables used in this analysis have an effect on the dependent variable of economic growth, because DT, IDT, and TIT have a significance level of 0.000, 0.000, and 0.000. The effect of the independent variables Direct tax, Indirect tax, and Tax on International Trade on economic growth can be explained by R Square = 98.9%.

# មាតិកា

ទំព័រ

ឧទ្ទិស្នាដៃ....i
អារម្ភកថា....ii
សេចក្តីថ្លែងអំណរគុណ....iii
អំណះអំណាង....iv
សេចក្តីសង្ខេបនៃការស្រាវជ្រាវ( ជាភាសាខ្មែរ )....v
សេចក្តីសង្ខេបនៃការស្រាវជ្រាវ( ជាភាសាអង់គ្លេស )....vi

## ជំពូកទី១

## សេចក្តីផ្តើម

១.១ លំនាំដើមនៃការស្រាវជ្រាវ....1
១.២ ការកំណត់បញ្ហានៃការស្រាវជ្រាវ....2
១.៣ គោលបំណងនៃការស្រាវជ្រាវ....3
១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ....3
១.៤.១ ទំហំ ដែនកំណត់....3
១.៤.២ វិសាលភាព....3
១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ....4
១.៥.១ ការប្រមូលទិន្នន័យដំបូង....4
១.៥.២ ការប្រមូលទិន្នន័យបន្ទាប់....4
១.៥.៣ វិធីសាស្ត្រនៃការវិភាគទិន្នន័យ....4
១.៥.៣.១ ឌីសស្រ្ក៏បទីវ ស្ត្រាស៊ីស្ទិច អាន់ណាឡាយស៊ីស....4
១.៥.៣.២ ក្លាសសិកខល អ៊ីសាំសិនតេស្ត....5
១.៥.៣.៣ ហាយផូស៊ីស តេស្តស៊ីង....5
១.៥.៣.៤ ម៉ាល់ធីផល រីក្រេសសិន អាន់ណាឡាយស៊ីស....5
១.៦ សារៈសំខាន់នៃការស្រាវជ្រាវ....6
១.៧ រចនាសម្ព័ន្ធនៃការសិក្សា....6

## ជំពូកទី២

## ការសិក្សារំលឹកទ្រឹស្តី

២.១ លក្ខណៈទូទៅរបស់ឥទ្ធិពលនៃពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា........8
២.១.១ និយមន័យពន្ធដារ........8
២.១.២ និយមន័យសេដ្ឋកិច្ច........8
២.១.៣ ការរំលឹកទ្រឹស្តីលើការសិក្សាកន្លងមក........9
២.២ ពន្ធដារជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជា........9
២.២.១ ពន្ធផ្ទាល់........9
២.២.២ ពន្ធប្រយោល........9
២.២.៣ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស........10
២.៣ ប្រភេទពន្ធដារដែរបានចូលរួមនៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា........10
២.៣.១ ប្រភេទពន្ធផ្ទាល់........10
២.៣.២ ប្រភេទពន្ធប្រយោល........11

## ជំពូកទី៣

## លទ្ធផលនៃការស្រាវជ្រាវ

៣.១ ប្រវត្តិនៃពន្ធដារ........12
៣.២ ស្ថានភាពទូទៅសេដ្ឋកិច្ច........13
៣.៣ ស្ថានភាពហិរញ្ញវត្ថុរបស់ពន្ធដារ........15
៣.៤ សម្មិតផលដែលពន្ធដារសម្រេចបាន........21
៣.៥ ចក្ខុវិស័យទៅថ្ងៃមុខរបស់ពន្ធដារ........21

## ជំពូកទី៤

## ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

៤.១ ការវិភាគលើចំណុចខ្លាំង........23
៤.២ ការវិភាគលើចំណុចខ្សោយ........24

# ជំពូកទី៥
# ការសន្និដ្ឋាន និងផ្តល់អនុសាសន៍

៥.១ សេចក្តីសន្និដ្ឋាន..........................................................................................................25
៥.២ ការផ្តល់អនុសាសន៍.....................................................................................................26

ឯកសារយោងជាភាសាខ្មែរ
ឯកសារយោងជាភាសាបរទេស
ឧបសម្ព័ន្ធ

# ជំពូកទី១
# សេចក្តីផ្តើម

## ១.១ លំនាំដើមនៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានផ្លាស់ប្តូរប្រព័ន្ធសេដ្ឋកិច្ចបែបផែនការ ទៅជាការអនុវត្តប្រពន្ធ័សេដ្ឋកិច្ចបែបទីផ្សារ ចាប់តាំងពីឆ្នាំ ១៩៩៣ មកម្លេះហើយយើងសង្កេតឃើញថាមានវិស័យជាច្រើន បានជ្រៀតចូលប្រទេសកម្ពុជាដែលធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានការរីកចម្រើនទៅមុខជាលំដាប់ ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ(១៩៩៣-២០១៨)។

ក្នុងចំណោមវិស័យអភិវឌ្ឍជាតិសំខាន់ៗវិស័យពន្ធដារក៏បានរួមចំណែកយ៉ាងធំធេង ក្នុងដំណើរការកសាង និងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជាឲ្យកាន់តែមានល្បឿនគួរឲ្យកាត់សម្គាល់។ យោងតាមរបាយការណ៍តួលេខ ដែលបោះផ្សាយដោយធនាគារពិភពលោក(WBG) កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ ២០១៦[1] បានបង្ហាញថាចំណូលជាតិដុល(GNI)ក្នុងពលរដ្ឋម្នាក់ៗនៅឆ្នាំ២០១៥ ស្មើនឹង១.០៧០ដុល្លារ ហើយតួលេខនេះមានចំនួនលើសពីកម្រិតគោលដែលស្មើនឹង១.០២៥ដុល្លារ សម្រាប់បណ្តាប្រទេសដែលមានចំណូលទាបដែលបានកំណត់សម្រាប់ឆ្នាំសារពើពន្ធ២០១៧។ ចំណែកការបោះផ្សាយតាមរយៈធនាគារពិភពលោក(WBG) កាលពីថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ បានបង្ហាញថាប្រទេសកម្ពុជាគឺសម្រេចបានកំណើន៧.៥ភាគរយ ក្នុងឆ្នាំ២០១៨ [2] ហើយបានប្រែក្លាយកម្ពុជាពីប្រទេសមួយនៃបណ្តាប្រទេសក្រីក្របំផុតលើពិភពលោក ទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាប។ បើពិនិត្យទៅមើលលើវិស័យពន្ធដារវិញ គឺជាផ្នែកមួយយ៉ាងសំខាន់នៃកំណើនសេដ្ឋកិច្ចជាតិ។

តាមសេចក្តីប្រកាសព័ត៌មាន នៃកិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែធ្នូ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានពន្ធដារបានបង្ហាញថា ចំណូលពន្ធដារទទួលបានពីវិស័យនេះមានប្រមាណជិតបីពាន់លានដុល្លារ កើនឡើង៣,៧៣ភាគរយ បើធៀបនឹងឆ្នាំ២០១៩។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបាននិយាយក្នុងកិច្ចប្រជុំនេះថា ទោះបីក្នុងដំណាក់កាលដ៏លំបាកនៃការឆ្លងរាលដាលជំងឺកូវីដនេះក៏ពិតមែនតែការប្រមូលពន្ធដារក្នុងឆ្នាំ២០២០ មិនបានធ្លាក់ចុះនោះទេ។ [3] សព្វថ្ងៃនេះពន្ធដារមិនត្រឹមតែដើរតួ

[1] របាយការណ៍នៃធនាគារពិភពលោក WORLD BANK ( ០១ កក្កដា ២០១៦ )

[2] របាយការណ៍បច្ចុប្បន្នភាពនៃ WORLD BANK ( ០៦ ឧសភា ២០១៩ )

[3] របាយការណ៍អគ្គនាយកដ្ឋានពន្ធដារប្រចាំខែធ្នូ ឆ្នាំ២០២០

យ៉ាងសំខាន់ដែលជាកម្លាំងជំរុញដល់កំណើនសេដ្ឋកិច្ចជាតិនោះទេ តែវាក៏បានរួមចំណែកដល់ការអភិវឌ្ឍសង្គមជាតិឲ្យមានការរីកចម្រើនជាលំដាប់។ ដោយមានការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅកម្ពុជា ក៏មានអ្នកវិនិយោគទុនជាតិ និង អន្តរជាតិជាច្រើនមកបង្កើតសហគ្រាសខ្នាតតូចនិងមធ្យមហើយវាក៏ដើរតួនាទីយ៉ាងសំខាន់មួយនៅក្នុងការបង្កើតការងារបង្កើតប្រាក់ចំណូលសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាបនិងប្រជាជនដែលងាយរងគ្រោះ និងជំរុញកំណើនសេដ្ឋកិច្ចស្ថេរភាពសង្គមនិងរួមចំណែកដល់ការរីកចម្រើនលើគ្រប់វិស័យ។

## ១.២ ការកំណត់បញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រ៥ឆ្នាំដំបូង ដើម្បីស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមគឺនៅឆ្នាំ ១៩៨៦-១៩៩០ ដែលបានផ្តល់អាទិភាពដល់ការអភិវឌ្ឍវិស័យកសិកម្មហេដ្ឋារចនាសម្ព័ន្ធ និងការកសាងឡើងវិញ។ កម្មវិធីនេះត្រូវបានអនុវត្តតាមកម្មវិធីជាតិឆ្នាំ១៩៩៤ ដើម្បីស្តារនិងអភិវឌ្ឍន៍ប្រទេសកម្ពុជាឡើងវិញ។ ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមលើកទីមួយត្រូវបានបង្កើតឡើងសម្រាប់ឆ្នាំ ១៩៩៦-២០០០ ដែលគាំទ្រដោយកម្មវិធីវិនិយោគសាធារណៈដែលជាកម្មវិធីវិនិយោគរំកិល៣ឆ្នាំ។ បន្ទាប់ពីកម្មវិធីនេះចក្ខុវិស័យនិងផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុលើកដំបូង[4]ត្រូវបានដាក់ឲ្យអនុវត្តក្នុងនោះក៏រួមមានការអនុម័តទៅលើយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រដែលបានចងក្រងឡើងនៅចុងឆ្នាំ ២០០២ ផងដែរ។[5] ចាប់តាំងពីឆ្នាំ ២០០៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(NSDPs) ត្រូវបានអនុវត្តយោងតាមយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារសមធម៌ និងប្រសិទ្ធភាព។ យុទ្ធសាស្ត្រចតុកោណដែលត្រូវបានធ្វើបច្ចុប្បន្នភាពជាទៀងទាត់ដែលត្រូវបានអនុម័តដោយរដ្ឋាភិបាលជាក្របខ័ណ្ឌណែនាំរបស់ជាតិ។ នៅក្នុងនេះផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបានសង្កត់ធ្ងន់ លើអភិបាលកិច្ចល្អដែលត្រូវបានចាត់ថាជាស្នូលនៃយុទ្ធសាស្ត្រចតុកោណក៏ដូចជាមូលដ្ឋានគ្រឹះនៃការអនុវត្តផ្សេងៗ ទៅលើសមតុល្យម៉ាក្រូសេដ្ឋកិច្ចក្នុងវិស័យពាណិជ្ជកម្មថវិកា និងអតិផរណា ក៏ដូចជាការជំរុញកំណើន និងការធ្វើពិពិធកម្ម។[6] គោលបំណងចម្បងនេះគឺដើម្បី

---

[4] ផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥» ថ្ងៃទី ២១ ខែតុលាឆ្នាំ២០១៦

[5] យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ ការប្រជុំគណៈរដ្ឋមន្ត្រីដំបូងនៃនីតិកាលទី ៣ នៃរដ្ឋសភាជាតិនៅទីស្តីការគណៈរដ្ឋមន្ត្រី» ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១៤។

[6] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ (NSDP) ២០១៩-២០២៣» ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩

ជានាបាននូវគុណភាពជីវិតល្អប្រសើរ សម្រាប់ប្រជាជនកម្ពុជានៅក្នុងសង្គមប្រជាធិបតេយ្យ។[7] ជាការពិតណាស់ប្រទេសកម្ពុជាប្ដេជ្ញា ក្នុងការក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

ហេតុដូចនេះគោលនយោបាយជាច្រើនត្រូវបានដាក់ចេញ ដើម្បីជានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ដែលស្ថិតនៅក្នុងរង្វង់កំណើនសេដ្ឋកិច្ច ៧% ក្នុងមួយឆ្នាំ ដើម្បីពង្រីកមូលដ្ឋានកំណើន និងលើកកម្ពស់ការប្រកួតប្រជែង ខណៈពេលដែលរក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច១០ និងលើកកម្ពស់ការបង្កើតគោលនយោបាយគ្រប់គ្រងហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ។[8]

ដោយយោងលើបញ្ហាប្រឈមខាងលើការចោទសួរសំខាន់ត្រូវបានលើកឡើងគឺៈ

១. តើពន្ធដារជះឥទ្ធិពលដល់កំណើនសេដ្ឋកិច្ចប្រទេសកម្ពុជាយ៉ាងដូចម្ដេច?

២. តើប្រភេទពន្ធដារអ្វីខ្លះបានចូលរួមនៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើការសិក្សារបស់យើងបានផ្ដោតលើនូវគោលបំណងសំខាន់ៗដូចខាងក្រោម ៖

- សិក្សាអំពីការរួមចំណែករបស់ពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា
- សិក្សាអំពីប្រភេទនៃពន្ធដារដែលមានរួមចំណែកដល់កំណើនសេដ្ឋកិច្ចកម្ពុជា

## ១.៤ ទំហំ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

### ១.៤.១ ទំហំ ដែនកំណត់

ការសិក្សាស្រាវជ្រាវនេះផ្ដោតទៅលើឥទ្ធិពលពន្ធដារលើកំណើនសេដ្ឋកិច្ចនៅកម្ពុជា ដោយសិក្សាលើពន្ធដារចំនួនបីប្រភេទ រួមមាន ពន្ធផ្ទាល់ ពន្ធប្រយោល និងពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។

### ១.៤.២ វិសាលភាព

យើងធ្វើការវិភាគទៅលើកំណើនសេដ្ឋកិច្ចនៅកម្ពុជាដែលជាការរួមចំណែករបស់ពន្ធដារទាំងបីប្រភេទខាងលើសម្រាប់រយៈពេលចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០២០។

## ១.៥ វិធីសាស្ត្រនៃការស្រាវជ្រាវ

[7] ការសិក្សាលើប្រទេសកម្ពុជាក្នុងការធ្វើពិពិធកម្មក្រៅពីវិស័យសម្លៀកបំពាក់ និងទេសចរណ៍» ខែវិច្ឆិកា ឆ្នាំ ២០១៤។

[8] យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា» ខែកញ្ញា ឆ្នាំ២០១៨

វិធីសាស្ត្រដែលត្រូវប្រើនៅក្នុងការសិក្សាស្រាវជ្រាវនេះរួមមានដូចជាប្រភេទនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការប្រមូលទិន្នន័យ ការកំណត់អញ្ញាត្តិនៃការសិក្សា វិធីសាស្ត្រនៃការវិភាគទិន្នន័យ និងការធ្វើតេស្តលើសម្មតិកម្ម ដែលបានកំណត់ក្នុងការសិក្សា ដើម្បីអាចវិភាគនិងពិភាក្សារកដំណោះស្រាយចំពោះសំណួរស្រាវជ្រាវរហូតឈានដល់ការសន្និដ្ឋាន។

**១.៥.១ ការប្រមូលទិន្នន័យដំបូង**

ការប្រមូលទិន្នន័យដំបូង ក្នុងការស្រាវជ្រាវនេះយើងបានប្រើប្រាស់នូវទិន្នន័យមានស្រាប់ ដែលឆ្លងកាត់ការធ្វើសវនកម្មរួចរាល់ដែលទិន្នន័យទាំងនេះយកចេញពីវេបសាយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលបានផ្សាយចេញចាប់ពីឆ្នាំ២០១០ ដល់ ២០២០។

**១.៥.២ ការប្រមូលទិន្នន័យបន្ទាប់**

ការប្រមូលទិន្នន័យបន្ទាប់ ការប្រើប្រាស់នូវប្រភេទឯកសារដែលមានការប្រមូលទិន្នន័យ ការកត់ត្រាទិន្នន័យ ដែលបោះពុម្ពផ្សាយតាមរយៈតារាងប្រតិបត្តិការហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**១.៥.៣ វិធីសាស្ត្រនៃការវិភាគទិន្នន័យ**

**១.៥.៣.១ ឌីស្រ្គីបទីវ ស្រ្តាស៊ីស្ទិច អាន់ណាឡាយស៊ីស** ( Descriptive StatisticsAnalysis )

យោងតាមលោក Nurgiyantoro ឆ្នាំ ២០០៤ បានរៀបរាប់ថា ការវិភាគស្ថិតិបែបពិពណ៌នាគឺជាបច្ចេកទេសមួយដែលផ្តល់ព័ត៌មានពិពណ៌នាអំពីទិន្នន័យដែលបានរក្សាទុក ដោយមិនមានគោលបំណងសម្រាប់ធ្វើតេស្តសម្មតិកម្មទេ។ការវិភាគនេះប្រើដើម្បីធ្វើបទបង្ហាញនិងវិភាគជាមួយនិងការគណនាបញ្ជាក់ពីកាលៈទេសៈឬលក្ខណៈទិន្នន័យក្នុងសំណួរ។ ការវាស់វែងដែលត្រូវប្រើក្នុងការសិក្សានេះគឺ Mean, Standard deviation, Maximum, Minimum, Skewness និង Kurtosis។ អតិផរណា( Maximum )គឺជាតម្លៃធំបំផុតក្នុងចំណោមទិន្នន័យទាំងអស់នៅក្នុងក្រុមតែមួយហើយអប្បបមា ( Minimum )គឺតម្លៃដែលតូចបំផុត។ Skewness និង Kurtosis ប្រើប្រាស់សម្រាប់ស្វែងរកនូវ Normal Distribution របស់ Data ដែលត្រូវបង្ហាញជារូបខ្សែកោង ២ ជាប់គ្នា។ Data Set ដែលមាន Normal Distribution មាន Skewness និងKurtosis ស្មើរក៏ប្រហាក់ប្រហែលនឹង0 នៅក្នុងលទ្ធផលនៃកម្មវិធី SPSS។ ខាងក្រោមនេះគឺជាច្បាប់មួយចំនួនចំពោះ Data Distribution លើ Skewness និង Kurtosisបើយោងតាមទៅតាមលោក Jim នៅឆ្នាំ ២០១៨៖

Skewness:

- ប្រសិនបើSkewnessតិចជាង-១ ច្រើនជាង១ នោះDistribution នៃខ្សែកោងវៀចទៅម្ខាងខ្លាំង
- ប្រសិនបើSkewnessចន្លោះពី-១និង-០.៥ ឬក៏ចន្លោះពី ០.៥និង១នោះDistributionវៀចទៅម្ខាងបន្តិច
- ប្រសិនបើSkewnessចន្លោះពី-០.៥ និង០. ៥ នោះ Distribution ប្រហាក់ប្រហែលមានភាពសីមេទ្រីគ្នា

Kurtosis: Kurtosis ដែលមានភាពវិជ្ជមានបង្ហាញនូវ Leptokurtic អថេរ ហើយKurtosis ដែលមានភាពអវិជ្ជមានបង្ហាញនូវ Platykurtic អថេរ។ Platykurtic មានចំនុចដៅរបាត់របាយ Leptokurticមានចំនុចចំនួនប្រហាក់ប្រហែលនឹងចំនួនមធ្យម។

**១.៥.៣.២ ក្លាសសិកខល អឹសាំសិនតេស្ត** ( Classical Assumption Test )

Classical Assumption Test ត្រូវបានគេប្រើប្រាស់សម្រាប់ធ្វើតេស្តរកភាពត្រឹមត្រូវនៃ Regression Model។ នៅក្នុងការស្រាវជ្រាវនេះធ្វើតេស្តលើ Normality Test, Multicollinearity Test និង Autocorrelation Test ត្រូវបានគេប្រើប្រាស់សម្រាប់បង្ហាញពីការទទួលយកបានឬមិនបាននៃ Regression Model។

**១.៥.៣.៣ ហាយផូស៊ីស តេស្តស៊ីង** ( Hypothesis Testing )

បន្ទាប់ពីធ្វើតេស្តលើ Normality Classical Assumptions Test រួចមកជំហានបន្ទាប់គឺត្រូវធ្វើតេស្តលើសម្មតិកម្មអស់។ឧបករណ៏ប្រើប្រាស់សម្រាប់ធ្វើការវិភាគមានCoefficients-Determination (R Square), F-test, និង T-test ។

**១.៥.៣.៤ ម៉ាល់ធីផល រីគ្រេសសិន អាន់ណាឡាយស៊ីស** ( Multiple Regression Analysis )

ការស្រាវជ្រាវនេះប្រើវិធីសាស្រ្ត Multiple Regression Analysis គឺជារបៀបឬមធ្យោបាយបែបស្ថិតិសម្រាប់ធ្វើការវិភាគផ្សារភ្ជាប់រវាងពីរឬច្រើននៃ អថេរឯករាជ្យ ( Independent Variable ) និងមួយ អថេរមិនឯករាជ្យ (Dependent Variables )។ ជាទូទៅ វាត្រូវបានប្រើប្រាស់ព្យាករណ៍នៃ Variable ជាក់លាក់មួយនឹងអាចត្រូវបាន ប្រើប្រាស់ធ្វើតេស្តលើសម្មតិកម្មបែបវិទ្យាសាស្រ្ត អំពីទំនាក់ទំនងរវាងអថេរឯករាជ្យ ( Independent Variable ) និង អថេរមិនឯករាជ្យ ( Dependent Variables )។ការវិភាគនេះ វាអាចឱ្យដឹងថាបម្រែបម្រួលនៃអថេរមិនឯករាជ្យ ( Dependent Variables ) មានការរងឥទ្ធិពលដោយបម្រែបម្រួល អថេរឯករាជ្យ ( Independent Variable )។

ទម្រង់សមីការនៃMultiple Regression Model នៅក្នុងការស្រាវជ្រាវនេះគឺ:

GDP = α + β1DT+ β2IDT + β3TIT + e

ដែល GDP ជា Dependent variable

DT= Direct Taxes
IDT= Indirect Taxes
TIT= Taxes International on Trade
α = Constant Value of Equation
β1 β2 β3 = Constant Value of Equation
e = error term of equation

## ១.៦ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះបានចូលរួមចំណែកៈ

1. រាជរដ្ឋាភិបាល/អ្នករៀបគោលនយោបាយសេដ្ឋកិច្ចនិងពន្ធដារ
   - ផ្ដល់ជាគំនិតថ្មីៗបន្ថែមទៀតនិងជាមតិយោបល់ដល់អ្នករៀបចំគោលនយោបាយសេដ្ឋកិច្ចរបស់ប្រទេស
   - ផ្ដល់អត្ថប្រយោជន៍ចំពោះអ្នកដឹកនាំម្ចាស់អាជីវកម្ម បុគ្គលិកក្នុងស្ថាប័នប្រជាពលរដ្ឋ ឱ្យយល់ដឹងឱ្យបានកាន់តែច្បាស់អំពីច្បាប់ពន្ធដារ
2. អ្នកសិក្សាស្រាវជ្រាវ
   - ទទួលបានចំណេះដឹងនិងបទពិសោធន៍ថ្មីៗជាច្រើនទៀត
   - ផ្ដល់នូវការយល់ដឹងបន្ថែមទៅលើព័ត៌មានដែលជាមូលដ្ឋានគ្រឹះដើម្បីគាំទ្រដល់ការស្រាវជ្រាវរបស់ពួកគេនាពេលអនាគត។
   - ជាឯកសារផ្ដល់យោបល់និងជាបទពិសោធន៍នៃការស្រាវជ្រាវខ្លះទុកសម្រាប់អ្នកជំនាន់ក្រោយ។

## ១.៧ រចនាសម្ព័ន្ធនៃការសិក្សា

ការសិក្សាស្រាវជ្រាវនេះចែកចេញជា៥ជំពូកគឺៈ

- ជំពូកទី១ៈ សេចក្ដីផ្ដើមៈ ទាក់ទងទៅនឹងលំនាំដើម ចំណោទបញ្ហា គោលបំណងនៃការសិក្សាស្រាវជ្រាវ ទំហំ ដែនកំណត់ វិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ និង រចនាសម្ពន្ធ័នៃការស្រាវជ្រាវ។
- ជំពូកទី២ៈ ការរំលឹកទ្រឹស្ដីៈ ពិនិត្យលើទ្រឹស្ដីដែលបានសិក្សានឹងស្រាវជ្រាវកន្លងមកនិងទាក់ទងទៅនឹងប្រធានបទ អញ្ញាតិទូទៅនៃពន្ធ ។

- ជំពូកទី៣៖ លទ្ធផលនៃការស្រាវជ្រាវ: ប្រវត្តិនៃពន្ធដារ ស្ថានភាពទូទៅនៃសេដ្ឋកិច្ច ពន្ធដារ និងស្ថានភាពហិរញ្ញវត្ថុរបស់ពន្ធដារ។
- ជំពូកទី៤៖ ការវិភាគ និងធ្វើការស្វែងយល់ពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រធានបទដែលពាក់ព័ន្ធ។
- ជំពូកទី៥៖ សេចក្តីសន្និដ្ឋាននិងអនុសាសន៍: ផ្តល់នូវអនុសាសន៍មួយចំនួនដើម្បីធ្វើឱ្យប្រសើរឡើងនូវការប្រមូលពន្ធនាំឲ្យកំណើនសេដ្ឋកិច្ចឱ្យមានប្រសិទ្ធភាពប្រសើរជាងមុន។

# ជំពូកទី២
# ការសិក្សារំលឹកទ្រឹស្តី

## ២.១ លក្ខណៈទូទៅរបស់ឥទ្ធិពលនៃពន្ធដារលើកំណើនសេដ្ឋកិច្ចកម្ពុជា

### ២.១.១ និយមន័យពន្ធដារ

ពន្ធដារគឺជា វិភាគទានដែរមានលក្ខណៈកាតព្វកិច្ចស្របតាមច្បាប់កំណត់ដែលអ្នកជាប់ពន្ធទាំងរូបវន្តបុគ្គល និងនីតិបុគ្គលត្រូវបង់ជូនរដ្ឋ។ ការយកពន្ធជាមធ្យោបាយជាក់ស្តែងមួយ ដែលរដ្ឋប្រើប្រាស់សម្រាប់បង្កើនប្រាក់ចំណូល និងបំពេញការចំណាយរបស់រដ្ឋទៅលើទំនិញ និងសេវាដែលប្រជាជនភាគច្រើនត្រូវការ ។ ទំនិញសាធារណៈដូចជា ការការពារជាតិ និងកម្មវិធីធានារ៉ាប់រងសង្គមអាចត្រូវបានផ្តល់ជូនសង្គមជាតិវិញតាមរយៈការយកពន្ធដោយចាប់បង្ខំប៉ុណ្ណោះ ពិតណាស់ប្រសិនបើរដ្ឋអនុញ្ញាតឲ្យប្រជាជន (អ្នកជាប់ពន្ធ)។[9]

### ២.១.២ និយមន័យសេដ្ឋកិច្ច

សេដ្ឋកិច្ច គឺសំដៅលើការយកពន្ធនិងវិធីរកចំនូលផ្សេងៗទៀតរបស់រដ្ឋ និងចំណាយដោយបែងចែកធនធានសេដ្ឋកិច្ចក្នុងគោលបំណងជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ប្រកបដោយចីរភាពនិងសមធម៌។

សេដ្ឋកិច្ច សិក្សាអំពីមនុស្សជាតិនៅក្នុងការងារជំនួញធម្មតានៃជីវិតរស់នៅ ។ តាមទ្រឹស្តីសេដ្ឋវិទូបានឱ្យនិយមន័យសេដ្ឋកិច្ចខុសៗគ្នាជាច្រើន ប៉ុន្តែន័យសុក្រឹតមួយគឺសេដ្ឋកិច្ចសិក្សាអំពីការប្រើប្រាស់បណ្តាលធនធានដ៏កម្រ ដើម្បីបំពេញសេចក្តីត្រូវការរបស់មនុស្សដែលគ្មានព្រំដែន។ មានទ្រឹស្តីមួយទៀតបាននិ-យាយថា សេដ្ឋកិច្ចជាការសិក្សាអំពីយុទ្ធសាស្ត្ររបៀបប្រើប្រាស់ធនធានដើម្បីបំពេញបំណងគ្មានព្រំដែនរបស់មនុស្សដែលមានប្រព័ន្ធទាក់ទិននឹងប្រព័ន្ធផលិតកម្ម (ផ្នែកសេដ្ឋកិច្ច និងឧស្សាហកម្ម)ប្រព័ន្ធបែងចែក (ផ្នែកពាណិជ្ជកម្ម) និងប្រព័ន្ធប្រើប្រាស់ទំនិញសេដ្ឋកិច្ច (ផ្នែកអតិថិជន ផ្នែកគមនាគមន៍និងដឹកជញ្ជូន )។ សេដ្ឋកិច្ច គឺជាសំណុំនៃទំនាក់ទំនង ផលិតកម្ម ការប្រើប្រាស់ ការទិញដូរ ការបែងចែងធនធានកម្រទាំងឡាយនៅក្នុងសង្គម ឬក៏ ទាក់ទងទៅនឹង។

សេដ្ឋកិច្ច មានពីរប្រភេទធំៗគឺ មីក្រូសេដ្ឋកិច្ច និង ម៉ាក្រូសេដ្ឋកិច្ច។ ប្រព័ន្ធសេដ្ឋកិច្ច ចែកចេញជាបីគឺ សេដ្ឋកិច្ចផែនការ សេដ្ឋកិច្ចទីផ្សារ និង សេដ្ឋកិច្ចចម្រុះ។[10]

### ២.១.៣ ការរំលឹកទ្រឹស្តីលើការសិក្សាកន្លងមក

9 អ្នកជាប់ពន្ធ៖ ប្រជាពលរដ្ឋទូទៅ អ្នកជាប់ពន្ធតូច អ្នកជាប់ពន្ធមធ្យម អ្នកជាប់ពន្ធធំ(អគ្គនាយកដ្ឋានពន្ធដារ)

10 គឺជាការរួមបញ្ចូលគ្នានូវយន្តការទីផ្សារ និងយន្តការរដ្ឋ( https://www.khsearch.com/qna/27813 )

ការស្រាវជ្រាវដែលទាក់ទងទៅពន្ធដារ ដើម្បីដឹងអំពីកំណើនសេដ្ឋកិច្ចធ្លាប់មានអ្នកសិក្សាជាច្រើនកន្លងមក។ អ្នកសិក្សាស្រាវជ្រាវទាំងអស់រួមមាន៖

លោក Mary, Martin, Mercy, Stephen Ibiunni និង Adebola Adetoyinbo (២០១៧)បានស្រាវជ្រាវលើប្រធានបទគឺ Impact of Direct and Indirect Tax on the Nigerian Economic Growth ចាប់ពីឆ្នាំ ១៩៩៤ ដល់ ២០១៣ ដែលយកទិន្នន័យជាធមាសនៃឆ្នាំនីមួយៗ។ លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា Direct tax and Indirect tax មានឥទ្ធិពលលើកំណើនសេដ្ឋកិច្ច។

លោក SUNA KORKMAZ, METHEHAN YILGOR, FARSIME AKSOY(២០១៩) បានស្រាវជ្រាវលើប្រធានបទគឺ The Impact of Direct and Indirect Tax on Economic Growth of the Turkish ចាប់ពីឆ្នាំ ២០០៦ ដល់ ២០១៨ ដែលយកទិន្នន័យជាត្រីមាសនៃឆ្នាំនីមួយៗ។ វិធីសាស្ត្រដែលគាត់ប្រើប្រាស់សម្រាប់សម្រាប់ធ្វើការស្រាវជ្រាវនេះគឺ Descriptive Statistics, ARDL model, Ordinary Least Squares by SPPS។ Dependent Variable នៃការសិក្សានេះគឺ GDP ហើយចំពោះ Independent Variable វិញមានDirect Taxes, Indirect Taxes។ លទ្ធផលនៃការស្រាវជ្រាវបង្ហាញថា Direct Taxes, Indirect tax មានឥទ្ធិពលលើកំណើនសេដ្ឋកិច្ច។

## ២.២ ពន្ធដារជះឥទ្ធិពលដល់កំណើនសេដ្ឋកច្ចប្រទេសកម្ពុជា

### ២.២.១ ពន្ធផ្ទាល់

ពន្ធផ្ទាល់ជាប្រភេទពន្ធ ដែលរដ្ឋាភិបាលប្រមូលដោយផ្ទាល់ពីបុគ្គលរងពន្ធ។ សេដ្ឋកិច្ចទីផ្សារមានអ្នកមាននិងអ្នកក្រ ដូចនេះលទ្ធភាពនៃការបង់ពន្ធមិនដូចគ្នាទេ។ ការបង់ពន្ធតិច ឬ ច្រើនអាស្រ័យទៅលើបុគ្គលម្នាក់ៗ។[11]

### ២.២.២ ពន្ធប្រយោល

ពន្ធប្រយោលគឺជារូបភាពប្រមូលពន្ធដោយប្រយោលតាមរយៈមនុស្សផ្សេងទៀត ដែលឆ្លងកាត់តាមថ្លៃទំនិញ ដែលអ្នកប្រើប្រាស់បានទិញ។ ពន្ធប្រយោលគឺត្រូវបង់ដោយមិនគិតពីកម្រិតនៃផលទុនរបស់អ្នកណាឡើយ វាប្រែប្រួលទៅតាមប្រភេទនៃផលិតផលដែលបានប្រើប្រាស់។[12]

### ២.២.៣ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស

11 ពន្ធផ្ទាល់៖ គឺជាប្រភេទពន្ធដែលរដ្ឋបាលកំណត់កម្មវត្ថុផ្ទាល់នៃពន្ធលើបុគ្គលឬទ្រព្យសម្បត្តិ ។ទ្រព្យសម្បត្តិដែលជាប់ពន្ធរួមមានចលនាទ្រព្យនិងអចលនទ្រព្យ ( https://www.khsearch.com/qna/29032 )

12 ពន្ធប្រយោល៖ គឺជាប្រភេទដែលមានកម្មវត្ថុជាការប្រើប្រាស់ទំនិញឬសេវាកម្ម ។ បន្ថែមពីលើនេះពន្ធប្រយោលគ្រប់ដណ្តប់ លើសសកម្មភាពផលិតផលដែរ ពីព្រោះទំនិញត្រូវបានដាក់អោយដាក់អោយឆ្លងកាត់ចលនាផលិតកម្ម ។

កម្ពុជាប្រមូលចំណូលពន្ធលើការធ្វើពាណិជ្ជកម្មក្រៅប្រទេស អនុវត្តន៍ការប្រមូលចំណូលសរុបបានចំនួនជាង ១ ០៦៩ ប៊ីលានរៀល ក្នុងនោះប្រមូលពន្ធអាករលើការនាំចូល បានជាង ១ ០៦០ ប៊ីលានរៀល រួមជាមួយពន្ធ និងអាករលើការនាំចេញបានចំនួនជិត ៩ ប៊ីលានរៀល។ ពាក់ព័ន្ធនិងការអនុវត្តពន្ធពាណិជ្ជ-កម្មក្រៅប្រទេស ក្នុងខែ មិថុនា ឆ្នាំ២០២០ អង្គភាពជំនាញអនុវត្តន៍ចំណូលពន្ធបានចំនួនជាង ១៥៧ ប៊ីលានរៀល ខណៈក្នុងខែឧសភា ការអនុវត្តប្រមូលពន្ធប្រភេទនេះ បានត្រឹមជាង ១៥២ប៊ីលានរៀល ក្នុងនោះគិតក្នុងរយៈពេល ៦ខែ ឆ្នាំ ២០២០ នេះ ការប្រមូលចំណូលពន្ធលើការធ្វើពាណិជ្ជកម្មក្រៅប្រទេស អនុវត្តន៍បានជាង ១,០៦៩ប៊ីលានរៀល ត្រូវប្រមាណជិត ៣៨% នៃច្បាប់ហិរញ្ញវត្ថុ ដែលបានកំណត់នៅក្នុងទំហំទឹកប្រាក់ប្រមាណ ២ ៧៦៩ប៊ីលានរៀល ។

ជុំវិញនិងការអនុវត្ត ពន្ធនៃការនាំចូលនេះវិញ ក្នុងនោះពន្ធសម្រាប់ការនាំចូលទំនិញផ្សេងៗ (លើកលែងប្រេងឥន្ធនៈ) សរុបបានប្រមាណ ៧៤៥ប៊ីលានរៀល ពន្ធគយលើផលិតផលគេលសិលា សរុបបានជិត ១៣២ ប៊ីលានរៀល អាករបន្ថែមលើផលិតផលគេលសិលាសម្រាប់ថែទាំផ្លូវថ្នល់ សរុបបានជាង ១៥១ ប៊ីលានរៀល ពន្ធនាំចូលទំនិញជាវត្ថុធាតុដើមសម្រាប់ផលិតឱសថ សរុបជាង ៨ប៊ីលានរៀល និងប្រភេទពន្ធនាំចូលផ្សេងៗទៀតមានចំនួនជាង ២២ប៊ីលានរៀល សរុបទាំងអស់សម្រាប់ចំណូលពន្ធលើពាណិជ្ជ-កម្មនាំចូល ការអនុវត្តបានប្រមាណជាង ១ ០៦០ ប៊ីលានរៀល ។ ចំណែកពន្ធនិងអាករលើការនាំចេញវិញ នៅក្នុងរយៈពេល ៦ខែនេះដែរក្នុងនោះអាករលើការនាំចេញឈើ មានចំនួនជិត ២.៦ ប៊ីលានរៀល អាករលើការនាំចេញកៅស៊ូមាន ៤.៥៩ប៊ីលានរៀល និងប្រភេទពន្ធលើការនាំចេញផ្សេងៗមាន ចំនួន ១.៧២ ប៊ីលានរៀល សរុបលើពន្ធនិងអាករលើការនាំចេញទាំងអស់អនុវត្តបានប្រមាណជិត ៩ប៊ីលានរៀល។[13]

## ២.៣ ប្រភេទពន្ធដារដែលប្រាទានចូលរួមនៅក្នុងកំណើនសេដ្ឋកច្ចកម្ពុជា

### ២.៣.១ ប្រភេទពន្ធផ្ទាល់

- ពន្ធលើប្រាក់ចំណូល
- ពន្ធលើការជួល
- ពន្ធលើដីធ្លីមិនប្រើប្រាស់
- ពន្ធប្រថាប់ត្រានិងពន្ធផ្ទេរកម្មសិទ្ធ
- ពន្ធប៉ាតង់

[13] ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស Aug 5, 2020

- ពន្ធលើប្រាក់បៀវត្ស
- ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនះគ្រប់ប្រភេទ
- ពន្ធសត្តឃាត
- ពន្ធតែម
- ពន្ធអប្បបរមា ។

**២.៣.២ ប្រភេទពន្ធប្រយោល**

- អាករលើតម្លៃបន្ថែម(VAT)
- ពន្ធអាករពិសេសលើទំនិញនិងសេវាមួយចំនួន
- អាករលើការបំភ្លឺសាធារណៈ
- អាករលើការស្នាក់នៅ
- អាករលើផលរបរ ។

# ជំពូកទី៣
# លទ្ធផលនៃការស្រាវជ្រាវ

នៅក្នុងជំពូកទី៣នេះមានគោលបំណងបង្ហាញពី លក្ខណៈនៃស្ថានភាពទូទៅរបស់ពន្ធដារ និង សេដ្ឋកិច្ច ដែលរួមមានដូចជា ប្រវត្តិរបស់ពន្ធដារ ស្ថានភាពសេដ្ឋកិច្ច ស្ថានភាពហិរញ្ញវត្ថុរបស់ពន្ធដារ ចំណាយរបស់រដ្ឋាភិបាល សម្មិតផលដែលពន្ធដារសម្រេចបាន និងចក្ខុវិស័យទៅថ្ងៃមុខរបស់ពន្ធដារ។ ព័ត៌មានឬទិន្នន័យដែលយើងខ្ញុំប្រើប្រាស់ក្នុងការសិក្សានេះជាប្រភេទទិន្នន័យដែលមានស្រាប់។

## ៣.១ ប្រវត្តិនៃពន្ធដារ

ពន្ធដារមានប្រវត្តិទាក់ទិនទៅនិងដំណើរការវិវត្តរបស់សង្គមវិទ្យាសាស្ត្រ មនុស្សសាស្ត្រសេដ្ឋកិច្ច និងតួនាទីដឹកនាំរបស់រដ្ឋាភិបាល កាលរាជានិយមខ្មែរសម័យអង្គរដែលកំណត់ទៅលើប្រទេសឡាវសៀម ភូមា និងសូម៉ាត្រាខាងជើងនូវដង្វាយក្នុងមួយឆ្នាំសម្រាប់ការជ្រកកោនក្រោមម្លប់ដ៏ត្រជាក់ និង សុខសាន្តរបស់គេពីការឈ្លានពានប្រទេសដទៃដោយមានការការពារពីមហានគរ។ កំឡុងពេលប្រទេសកម្ពុជាបានធ្លាក់ក្រោមអាណានិគមនិយមបារាំង។ បារាំងបានអនុវត្តទស្សនះវិជ្ជារបស់ហ្សង់សាក់រូសូដ៏ល្បីល្បាញដែលលោកបានពោលថា ធម្មជាតិនៃជីវិតមនុស្សគឺបរិសុទ្ធប៉ុន្តែសង្គមទេដែលកែច្នៃភាពបរិសុទ្ធរបស់មនុស្ស។ ដោយយោងលើទស្សនះនេះហើយមនុស្សត្រូវតែបែងចែកចំណូលគ្នា ទើបសមជាសង្គមមនុស្សពិត។ រាស្ត្រ និងស្តេចជាមនុស្សដូចគ្នា ហើយគេមានកាតព្វកិច្ចបង់ពន្ធដូចគ្នាទៅតាមសមាមាត្រចំណូល។

ឆ្នាំ ១៩២៥ វិបត្តិកើតមាននៅប្រទេសកម្ពុជាសម័យអាណានិគមនិយមបារាំងគឺមនុស្សទាំងអស់ត្រូវបង់ពន្ធជូនបារាំង(រឿងភូមិតិរិច្ឆាន១៩៦៤ ដល់ ១៩៦៥)។ ការអត់ធ្មត់យ៉ាងវេទនា និងភាពបរិសុទ្ធរបស់ពុទ្ធសាសនិកត្រូវបានកេងប្រវ័ញ្ច ហើយរាស្រ្តខ្មែរធ្វើការតវ៉ាប្រឆាំង។ បារាំងមិនបានយកពន្ធអាករដែលប្រមូលបានទៅអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា និងអ្នកក្រីក្រខ្មែរនោះទេ។ ស្រមោលខ្មៅនៃអាណានិគមនិយមបារាំងបានចាកចេញផុតពីប្រទេសកម្ពុជាក្រោមការទាមទារឯករាជ្យរបស់ ស៊ីងង៉ុកមិញ និង សម្តេចសីហនុ។ ឆ្នាំ១៩៥៣ ប្រទេសកម្ពុជាទទួលបានឯករាជ្យហើយរៀបចំបង្កើតនាយកដ្ឋានពន្ធគយរដ្ឋាករពន្ធដារដំបូងនៅក្នុងប្រទេសកម្ពុជាតាមតម្រូវការនៃកំណើនសេដ្ឋកិច្ច។ ភាពសុខសាន្តនៃប្រជារាស្ត្រខ្មែរបានតែជាងមួយទស្សវត្សបន្តិចក៏ត្រូវបានបាត់បង់ទៅវិញដោយសារភាពទុំមុនស្រគាលនៃអ្នកនយោបាយខ្មែរ ពួកគេបានលើកចង្កេរទ្រព្យ និងសុកមង្គមរបស់រាស្ត្រទៅដាក់ក្នុងភ្លើងសង្គ្រាម។[14]

[14] រឿងភូមិតិរច្ឆាន(១៩៦៤-១៩៦៥)

របបរាស្ត្រនិយមថ្មី និងពហុបក្សបាននាំមកនូវសន្តិភាពចាប់ពីឆ្នាំ១៩៩៣ ត្រូវបានលើកយកមកពិភាក្សាតាមរយៈតួនាទីរបស់រដ្ឋាភិបាលគឺការផ្តល់នូវសម្ភារៈនិងសេវាកម្មការបែងចែកចំណូលមកពិភាក្សាតាមរយៈតួនាទីរបស់រដ្ឋាភិបាលគឺការផ្តល់នូវសម្ភារៈនិងសេវាកម្មការបែងចែកចំណូលឡើងវិញ ពន្ធដារច្បាប់ប្រតិបត្តិ ជំនួញឬនយោបាយការពារ។ ចាប់តាំងពីពេលនោះមកប្រព័ន្ធពន្ធដារនៅប្រទេសម្ពុជាមានលក្ខណៈល្អប្រសើរជាងមុនបន្តិចម្តងៗរហូតមកដល់ពេលបច្ចុប្បន្ននេះគិតត្រឹមឆ្នាំ២០២១។

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារបានអះអាងថាការប្រមូលចំណូលពន្ធរយៈពេល៥ឆ្នាំចុងក្រោយនេះឃើញថាចំណូលពន្ធដារបានកើនឡើងក្នុងរង្វង់ ២០%ក្នុងមួយឆ្នាំ។ បើនិយាយពីស្ថាប័នរដ្ឋប្រមូលចំណូលជូនជាតិសំខាន់ៗក្រៅពីអគ្គនាយកដ្ឋានពន្ធដារនេះក៏មានស្ថាប័នប្រមូលចំណូលមួយទៀតក៏សំខាន់ណាស់ដែរគឺអគ្គនាយកដ្ឋានគយនិងរដ្ឋាករ។ តួយ៉ាងរបាយការណ៍ប្រចាំឆ្នាំរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករបានបង្ហាញឲ្យដឹងថា នៅឆ្នាំ ២០១៨ ចំណូលពន្ធគយដែលប្រមូលបានមានជាង ២.៥០០ លានដុល្លារអាមេរិក ពោលគឺខ្ពស់ជាងចំណូលពន្ធដារ ៣០០ លានដុល្លារអាមេរិក។ ពន្ធដារផ្តល់នៅភាពងាយស្រួលក្នុងការផ្តល់សាវាកម្មនៅទីស្នាក់កាកណ្តាលនិងគ្រប់៣៣សាខាទាំងក្នុងរាជធានីភ្នំពេញ និងតាមបណ្តាលខេត្តផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា។ នៅរាជធានីភ្នំពេញពន្ធដារមានចំនួន ៩សាខា និងតាមបណ្តាលខេត្តមានចំនួន ២៤សាខា។[15]

## ៣.២ ស្ថានភាពទូទៅសេដ្ឋកិច្ច

នៅក្នុងអំឡុងពេលជាងពីរទសវត្សរ៍កន្លងទៅ ប្រទេសកម្ពុជាមានការផ្លាស់ប្តូរីកចម្រើនគួរឲ្យកត់សម្គាល់ដោយឈានទៅទទួលបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុងឆ្នាំ ២០១៥ ហើយប្រាថ្នាថា និងសម្រេចឲ្យបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០។ ដោយមានវិស័យនាំចេញសម្លៀកបំពាក់ និងទេសចរណ៍ជាអ្នកនាំមុខ សេដ្ឋកិច្ចរបស់កម្ពុជារក្សាបានកំណើនជាមធ្យម ៨ ភាគរយក្នុងមួយឆ្នាំ រវាងឆ្នាំ១៩៩៨ និងឆ្នាំ២០១៨ ដែលដាក់ប្រទេសនេះក្នុងចំណោមប្រទេសដែលសេដ្ឋកិច្ចមានកំណើនលឿនជាងគេនៅលើពិភពលោក។ កំណើនសេដ្ឋកិច្ចនៅតែរក្សាបានភាពរឹងមាំតាមការគន់គូរទុកជាមុនវាអាចកើនឡើងដល់ទៅ ៧,១ភាគរយក្នុងឆ្នាំ២០១៩ ដោយសារតែការនាំចេញសម្រេចបានកំណើនខ្ពស់ជាងការរំពឹងទុក គឺ៧,៥ភាគរយក្នុងឆ្នាំ២០១៨។

[15] សៀវភៅពន្ធដាររបស់លោកគ្រូសាស្ត្រាចារ្យ ដួង កណ្ណារ៉ា(២០២០-២០២១)

វិបត្តិពិភពលោកដែលបង្កឡើងដោយការឆ្លងរាលដាលនៃជំងឺ កូវីដ១៩ បានធ្វើឲ្យប៉ះពាល់ដល់សេដ្ឋកិច្ចកម្ពុជាយ៉ាងខ្លាំងក្នុងឆ្នាំ ២០២០ នេះ វាស្របពេលដែលកម្ពុជាក៏ប្រឈម និងការលុបចោលផ្នែកខ្លះនៃភាពអនុគ្រោះពាណិជ្ជកម្មក្រោមប្រព័ន្ធ «ទំនិញគ្រប់មុខលើកលែងតែអាវុធ»(EBA)របស់សហភាពអឺរ៉ុប។ ការឆ្លងរាលដាលនេះបានបង្កឲ្យមានការធ្លាក់ចុះយ៉ាងគំហុកនូវស្ទើរគ្រប់ផ្នែកនៃក្បាលម៉ាស៊ីនដែលជំរុញឲ្យមានកំណើនសេដ្ឋកិច្ចនៃត្រីមាសទី១ ឆ្នាំ២០២០នេះ រួមទាំងវិស័យទេសចរណ៍ និងសកម្មភាពសំណង់។ កំណើនត្រូវបានប៉ាន់ប្រមាណថានិងថយចុះយ៉ាងខ្លាំងមកនៅត្រឹម ២,៥ ភាគរយក្នុងឆ្នាំ ២០២០ ក្នុងសេនារីយោខ្សែបន្ទាត់គោល។ ការផ្ទុះនៃជំងឺកូវីដ-១៩នេះ និងការងើបឡើងវិញយឺតៗនៃ សកម្មភាពសេដ្ឋ-កិច្ចសាកលលោក រួមទាំងចលាចលលើទីផ្សារហិរញ្ញវត្ថុអូសបន្លាយ និង ធ្វើឲ្យមានហានិភ័យដល់ចក្ខុវិស័យកំណើនរបស់កម្ពុជា។ ភាពក្រីក្រនៅកម្ពុជាបន្តធ្លាក់ចុះតាមការប៉ាន់ស្មានមើលអត្រាភាពក្រីក្រក្នុងឆ្នាំ ២០១៤ មានកម្រិត ១៣,៥ ភាគរយក ប្រៀបធៀបទៅនឹង៤៧,៨ភាគរយៈក្នុងឆ្នាំ២០០៧ជិត៩០ភាគរយនៃជនក្រក្រីរស់នៅតាមទីជនបទ។ ទោះបីជាប្រទេសកម្ពុជាសម្រេចបានគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ដោយកាត់បន្ថយភាពក្រីក្របានពាក់កណ្តាលនៅក្នុងឆ្នាំ ២០០៩ ក៏ពិតមែន ប៉ុន្តែភាគច្រើនលើសលប់នៃគ្រួសារដែលគេចផុតពីភាពក្រីក្រ គឺបានគេចផុតទាំងប៉ផុតប៉ផើយ។ ពលរដ្ឋជិត ៤,៥លាននាក់ កំពុងរស់នៅក្បែរគែមនៃភាពក្រីក្រ ដែលធ្វើឱ្យពួកគេងាយរងគ្រោះធ្លាក់ចុះក្នុងភាពក្រីក្រវិញណាស់ កាលណាត្រូវប្រឈមទៅនឹងស្ថានភាពកន្ត្រាក់ផ្នែកសេដ្ឋកិច្ចឬកត្តាខាងក្រៅណាផ្សេងទៀត។

ទោះបីជាលទ្ធផលក្នុងវិស័យសុខាភិបាលនិងអប់រំឃើញថាមានវឌ្ឍនភាពពិតមែន ប៉ុន្តែសូចនាកររបស់មូលធនមនុស្សនៅតែមានភាពយឺតយ៉ាវនៅឡើយធៀប នឹង ប្រទេសដែលមានចំណូលមធ្យមកម្រិតទាបដូចគ្នា។

ជាក់ស្តែង ទារកម្នាក់ដែលកើតថ្ងៃនេះនឹងមានផលិតភាពផ្នែកសេដ្ឋកិច្ចខ្ពស់បំផុតបានត្រឹមតែ ៤៩ ភាគរយទេនៅពេលដែលគេធំពេញវ័យ នោះប្រសិនបើគេទទួលបានការអប់រំពេញលេញ មានសុខភាពល្អ និងបរិភោគអាហារមានអាហារូបត្ថម្ភត្រឹមត្រូវក្នុងអំឡុងពេលកុមារភាព។ កុមារមួយនាក់ក្នុងចំណោមបីនាក់ដែលមានអាយុក្រោមប្រាំឆ្នាំមានជំងឺក្រិន ហើយមានតែ៣៦ភាគរយប៉ុណ្ណោះនៃកុមារអាយុពីបីទៅប្រាំឆ្នាំដែលចូលរៀនកម្រិតមត្តេយ្យសាលា។ ខណៈដែលអត្រារៀនចប់កម្រិតបឋមសិក្សាបានកើនពី ៨២ ភាគរយក្នុងឆ្នាំ១៩៩៧ ដល់៩៧ភាគរយក្នុងឆ្នាំ២០១៦ក៏ពិតមែន អត្រារៀនចប់កម្រិតមធ្យមសិក្សាចំណេះទូទៅមានត្រឹមតែ ៥៧ភាគរយទេក្នុងឆ្នាំ២០១៧ ដែលជាអត្រាមួយទាបជាងអត្រាមធ្យមសម្រាប់បណ្តា

ប្រទេសមានចំណូលមធ្យមទាបទៅទៀត។ ហេតុនេះការកែទម្រង់សំខាន់ៗគឺជាភាពចាំបាច់ដើម្បីឱ្យកម្ពុជាអាចរក្សាបានកំណើនសេដ្ឋកិច្ចដែលជួយដល់ជនក្រីក្រ ស្ទួយភាពប្រកួតប្រជែងរបស់ប្រទេស គ្រប់គ្រងសម្បត្តិធនធានធម្មជាតិឱ្យមានចីរភាព និងកែលម្អឱ្យកាន់តែប្រសើរឡើងនូវគុណភាពនិងលទ្ធភាពរបស់ពលរដ្ឋក្នុងការទទួលបានសេវាសាធារណៈ។

ប្រទេសកម្ពុជា នៅតែបន្តជួបការខ្វះខាតខ្លាំងក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ប៉ុន្តែនឹងទទួលបាននូវអត្ថប្រយោជន៍ ជាច្រើនវិញពីការតភ្ជាប់បណ្តាញគមនាគមន៍កាន់តែទូលំទូលាយជាងមុន អាស្រ័យហេតុនេះការវិនិយោគទៅលើហេដ្ឋារចនាសម្ព័ន្ធនៅទីជនបទ និងទីប្រជុំជនគឺជារឿងមួយសំខាន់ខ្លាំងណាស់។ ការបន្តធ្វើពិពិធកម្មសេដ្ឋកិច្ចនឹងតម្រូវឱ្យមានការលើកស្ទួយសហគ្រិនភាពឱ្យពង្រីកការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងកសាងជំនាញថ្មីៗ ដើម្បីឆ្លើយតបទៅនឹងភាពចាំបាច់របស់ទីផ្សារពលកម្មថ្មីដែលកំពុងលេចមុខឡើង។ ស្ថាប័នសាធារណៈដែលមានគណនេយ្យភាពដែលរហ័ស រហួន ក៏ជារឿងមួយទៀតដែលមានសារៈសំខាន់ខ្លាំងដែរ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពលរដ្ឋ និងរបស់វិស័យឯកជន ដែលមានការវិវត្តឥតឈប់ឈរ។ គុណភាពរបស់មូលធនមនុស្សកាន់តែមានសារៈសំខាន់បំផុតលើសអ្វីៗទាំងអស់ដើម្បីកម្ពុជាឈានទៅសម្រេចគោលដៅប្រកបដោយមហិច្ឆតារបស់ខ្លួនក្នុងការប្រែក្លាយប្រទេសឱ្យទៅជាសេដ្ឋកិច្ចមានចំណូលមធ្យមត្រឹមឆ្នាំ២០៣០។[16]

## ៣.៣ ស្ថានភាពហិរញ្ញវត្ថុរបស់ពន្ធដារ

❖ តារាងទី៣-១ ៖ តារាងសង្ខេបចំណូលពន្ធដារឆ្នាំ២០១០ដល់២០២០ចំណូលពន្ធ (គិតជាប៊ីលានរៀល)

| ឆ្នាំ/ត្រីមាស[17] | ពន្ធផ្ទាល់ | ពន្ធប្រយោល | ពន្ធពាណិជ្ជកម្មក្រៅប្រទេស |
|---|---|---|---|
| **2020** | 5760.31 | 11244.02 | 21209.84 |
| **1** | 910 | 3166.60 | 5539.68 |
| **2** | 2409.41 | 2378.40 | 5589.68 |
| **3** | 944.9 | 2449.02 | 4190.44 |
| **4** | 1496 | 3250.00 | 5890.04 |
| **2019** | 3887.18 | 13812.62 | 24749.48 |
| **1** | 1003.35 | 2901.48 | 5097.49 |
| **2** | 612.13 | 3332.80 | 6357.14 |

16 ធនាគារពិភពលោក 16 មេសា 2020

17 ការអនុវត្តថវិការដ្ឋឆ្នាំ២០១០ ដល់ ២០២០

| | | | |
|---|---|---|---|
| **3** | 907.8 | 3726.32 | 6364.51 |
| **4** | 1363.9 | 3852.02 | 6930.34 |
| **2018** | 3886.99 | 10761.39 | 19743.14 |
| **1** | 978.81 | 2491 | 4357.64 |
| **2** | 1279.6 | 2570.8 | 5080.62 |
| **3** | 803.74 | 2621.19 | 4670.25 |
| **4** | 824.84 | 3078.40 | 5634.63 |
| **2017** | 3764.42 | 7678.14 | 16648.26 |
| **1** | 1278.83 | 1280.07 | 4310.46 |
| **2** | 1136 | 1971.6 | 4093.53 |
| **3** | 727.35 | 2120.27 | 3922.55 |
| **4** | 622.24 | 2306.2 | 4321.72 |
| **2016** | 2952.48 | 7233.38 | 14202.05 |
| **1** | 897.25 | 1818.09 | 3533.09 |
| **2** | 982.05 | 1872.49 | 3849.68 |
| **3** | 577.74 | 1800.8 | 3414.28 |
| **4** | 495.44 | 1742 | 3405 |
| **2015** | 2646.71 | 3554.24 | 11879.93 |
| **1** | 598.71 | 838 | 2647.8 |
| **2** | 900.9 | 853.82 | 3301.56 |
| **3** | 490.8 | 1000.94 | 3063.27 |
| **4** | 656.3 | 861.48 | 2867.3 |
| **2014** | 1479.14 | 2990.93 | 10603.21 |
| **1** | 291.7 | 729.16 | 2220.49 |
| **2** | 632.82 | 465.35 | 2838.66 |
| **3** | 291.43 | 859.09 | 2595.43 |
| **4** | 263.19 | 937.33 | 2948.63 |
| **2013** | 1184.06 | 2705.56 | 8773.77 |
| **1** | 248.42 | 554.64 | 1823.61 |
| **2** | 511.11 | 635.8 | 2252.85 |
| **3** | 194.6 | 674.9 | 1868.85 |
| **4** | 229.93 | 840.22 | 2828.46 |
| **2012** | 976.86 | 2399.62 | 8143.54 |
| **1** | 199.6 | 470.72 | 1728.95 |
| **2** | 389.01 | 575.43 | 2045.07 |
| **3** | 207.16 | 608.09 | 1900.8 |
| **4** | 181.09 | 745.38 | 2468.72 |
| **2011** | 723.87 | 1943.05 | 6444.81 |
| **1** | 169.64 | 385.37 | 1407.19 |

| | | | |
|---|---|---|---|
| **2** | 261.03 | 444.09 | 1519.47 |
| **3** | 139.9 | 497.47 | 1510.12 |
| **4** | 153.3 | 616.12 | 2008.03 |
| **2010** | 602.65 | 1672.5 | 5868.69 |
| **1** | 155.8 | 374.1 | 1424.61 |
| **2** | 182.45 | 403.9 | 1341.1 |
| **3** | 147.12 | 461.8 | 1427.95 |
| **4** | 117.28 | 432.7 | 1675.03 |

តាមរយៈតារាងខាងលើនេះបានបង្ហាញពីចំណូលសរុបនៃពន្ធទាំង៣រួមមាន ពន្ធផ្ទាល់ ពន្ធប្រយោល ពន្ធពាណិជ្ជកម្មក្រៅប្រទេស ដែលមានរយៈពេល១០ឆ្នាំចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០២០។

- រូបភាពទី៣-១: ក្រាបពន្ធផ្ទាល់




តាមរយៈក្រាបនេះបង្ហាញថាការប្រមូលពន្ធនៃពន្ធផ្ទាល់ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩ មានការកើនឡើងបន្តិចម្តងៗ តែនៅឆ្នាំ២០២០មានការថយចុះ។

- រូបភាពទី៣-២: ក្រាបពន្ធប្រយោល




តាមរយៈក្រាបនេះបង្ហាញថាការប្រមូលពន្ធនៃពន្ធប្រយោល ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៦មានការកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ តែមកដល់ឆ្នាំ២០១៧មានការថយចុះជាងឆ្នាំ២០១៦ ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩មានការកើនឡើងខ្ពស់ ប៉ុន្តែមកដល់ឆ្នាំ២០២០មានការធ្លាក់ចុះ។

- រូបភាពទី៣-៣: ក្រាបពន្ធលើពាណិជ្ជកម្មក្រៅប្រទេស




តាមរយៈក្រាបនេះបង្ហាញថាការប្រមូលពន្ធនៃពន្ធលើពាណិជ្ជកម្មក្រៅប្រទេសចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩មានការកើនឡើង ប៉ុន្តែនៅក្នុងឆ្នាំ២០២០មានការថយចុះ។

- រូបភាពទី៣-៤: ការប្រៀបធៀបចំណូលនៃការប្រមូលពន្ធនៃពន្ធទាំងបី




តាមរយៈការសិក្សាក្រាបខាងលើបង្ហាញថាចំណូលនៃពន្ធប្រយោលប្រមូលបានចំណូលខ្ពស់ជាង បន្ទាប់មកពន្ធផ្ទាល់ ពន្ធដែលមានចំណូលទាបជាងគេគឺពន្ធលើពាណិជ្ជកម្មក្រៅប្រទេស។

❖ តារាងទី៣-២[18]: តារាងតម្លៃនៃGDP ចាប់ពីឆ្នាំ២០១០ដល់២០២០ (គិតជាប៊ីលានរៀល)

| ឆ្នាំ | ត្រីមាសទី1 | ត្រីមាសទី2 | ត្រីមាសទី3 | ត្រីមាសទី4 |
|---|---|---|---|---|
| 2020 | 1424.61 | 1341.1 | 1427.95 | 1675.03 |
| 2019 | 1407.19 | 1519.47 | 1510.12 | 2008.03 |
| 2018 | 1728.95 | 2045.07 | 1900.8 | 2468.72 |
| 2017 | 1823.61 | 2252.85 | 1868.85 | 2828.46 |

[18] ការអនុវត្តថវិកាជាតិ(២០១០-២០២០)

| | | | | |
|---|---|---|---|---|
| 2016 | 2220.49 | 2838.66 | 2595.43 | 2948.63 |
| 2015 | 2647.8 | 3301.56 | 3063.27 | 2867.3 |
| 2014 | 3533.09 | 3849.68 | 3414.28 | 3405 |
| 2013 | 4310.46 | 4093.53 | 3922.55 | 4321.72 |
| 2012 | 4357.64 | 5080.62 | 4670.25 | 5634.63 |
| 2011 | 5097.49 | 6357.14 | 6364.51 | 6930.34 |
| 2010 | 5539.68 | 5589.68 | 4190.44 | 5890.04 |

- រូបភាពទី៣-៥: ក្រាបតម្លៃនៃGDP ចាប់ពីឆ្នាំ២០១០ដល់២០២០(គិតជាប៊ីលានរៀល)




តាមរយៈការសិក្សាក្រាបខាងលើបង្ហាញថាចំណូលGDP ចាប់ពីឆ្នាំ២០១០ដល់ឆ្នាំ២០១៩មានការកើនឡើងជាលំដាប់ ប៉ុន្តែនៅក្នុងឆ្នាំ២០១៩មានការថយចុះ រហូតមកដល់ឆ្នាំ២០២០មានការកើនឡើងបន្តិចវិញ។

## ៣.៤ សមិទ្ធផលដែលពន្ធដារសម្រេចបាន

អគ្គនាយកដ្ឋានពន្ធដារអាចនិយាយបានថា ជាដៃឆ្វេងដ៏សំខាន់របស់រាជរដ្ឋាភិបាលក្នុងការប្រមូលចំណូលចូលឃ្លាំងជាតិបន្ទាប់ពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករដែលជាដៃស្តាំ។ បើតាមរបាយការណ៍ពីអគ្គ-នាយកដ្ឋានពន្ធដារនៅបីខែដំបូងនៃឆ្នាំ ២០១៩ នេះពោលរាប់ចាប់ពីខែមករាដល់ខែមីនារាជរដ្ឋាភិបាលកម្ពុជាប្រមូលចំណូលពន្ធដារនិងអាករប្រមាណជាង ៨០០ លានដុល្លារអាមេរិកស្មើនឹងជាង ៣៦% នៃផែនការប្រចាំឆ្នាំ បើធៀបនឹងត្រីមាសទី១កាលពីឆ្នាំ២០១៨ឃើញថាមានកំណើនជាង ១២%។

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធរបានឲ្យដឹងថា៣ខែដំបូងនៃឆ្នាំនេះចំណូលពន្ធមានការកើនឡើងខ្ពស់ជាង៣ខែដើមឆ្នាំមុនប្រមាណជាង ៧៣ លានដុល្លារអាមេរិកឬស្មើនឹងកំណើនជាង ១២%។ បើគិតត្រឹមតែខែមីនាមួយប៉ុណ្ណោះចំណូលពន្ធអាករដែលអគ្គនាយដ្ឋានពន្ធដារប្រមូលបានមានចំនួនជាង ៤៧៦ លានដុល្លារអាមេរិកស្មើនឹងជិត ២១% នៃផែនការប្រចាំឆ្នាំបើធៀបនឹងខែមីនាកាលពីឆ្នាំ ២០១៨ ឃើញថាមានការកើនឡើងជាង ៦%។ គួររំឭកបន្តិចដែរថានៅពេញមួយឆ្នាំ ២០១៨កន្លងទៅនេះ អគ្គនាយកដ្ឋានពន្ធដារក៏បានប្រមូលពន្ធអាករគ្រប់ប្រភេទតាមប្រព័ន្ធគ្រប់គ្រងទិន្នន័យចំណូលអនឡាញសរុបមានប្រមាណ ២.២០០ លានដុល្លារអាមេរិកដែលស្មើនឹងប្រមាណជាង ១១៤% នៃផែនការប្រចាំឆ្នាំដែលបាននៃផែនការប្រចាំឆ្នាំដែលបានកំណត់ ពោលមានការកើនឡើងជាង ១៣%ធៀបនឹង២០១៧។[19]

## ៣.៥ ចក្ខុវិស័យទៅថ្ងៃមុខរបស់ពន្ធដារ

កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៧ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានបង្ហាញពីឱកាសវិនិយោគនៅកម្ពុជាក្នុងបរិយាកាសប្រទេសជាតិប្រកបដោយសុខសន្តិភាព ស្ថេរភាពនយោបាយសេដ្ឋកិច្ចរីកចម្រើននិងជាពិសេសការរក្សានៅកំណើនសេដ្ឋកិច្ចថេរក្នុងអត្រារង្វង់លើស ៧,៧ភាគរយក្នុងមួយឆ្នាំសម្រាប់រយៈពេល ២ ទសវត្សកន្លងមក។ ខណៈនេះប្រទេស កម្ពុជារក្សាបាននូវកម្រិតអតិផរណាទាបនឹងអាចគ្រប់គ្រងបាន( គិតជាមធ្យម ២,៨ភាគរយក្នុងមួយឆ្នាំ រយៈពេល ៥ឆ្នាំចុងក្រោយ)អត្រាប្តូរប្រាក់ថេរ ពលកម្មដែលមានភាពទាក់ទាញ អត្រាពន្ធទាបជាងប្រទេសនានាក្នុងតំបន់ ជាពិសេសការលើកលែងពន្ធ (Tax Holiday) អតិបរមា៩ឆ្នាំសម្រាប់វិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់(QIP) និងការលើកទឹកចិត្តផ្នែកពន្ធដារចំពោះវិស័យផ្សេងៗទៀតព្រមទាំងមូលដ្ឋានគ្រឹះសំខាន់ៗ

[19] ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្សេងទៀតដែលជាយន្តការនៃការទាក់ទាញវិនិយោគិនមកវិនិយោគនៅប្រទេសកម្ពុជា។ ជាការគិតគូរបន្ថែមអំពីការរកទទួលទាននៅកម្ពុជា យន្តការនៃភាពជាដៃគូរបស់រដ្ឋាភិបាល និងវិស័យឯកជនត្រូវបានបង្កើតឡើងនិងយកចិត្តទុកដាក់តាមរយៈគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥ ដល់ ២០២៥ កម្ពុជាមានចក្ខុវិស័យ និងយុទ្ធសាស្រ្តច្បាស់លាស់ក្នុងការទាក់ទាញនិងជំរុញការវិនិយោគនៅ កម្ពុជា។

បន្ថែមពីលើនេះ ប្រតិភូរាជរដ្ឋាភិបាលក៏បានបង្ហាញអំពីប្រព័ន្ធពន្ធនៅកម្ពុជា ដោយបានពន្យល់ពីប្រភេទពន្ធសំខាន់ៗ និងនិតិវិធីនៃការអនុវត្តគ្រប់គ្រងប្រមូលពន្ធ ព្រមទាំងគោលនយោនបាយពន្ធដាររបស់រដ្ឋាភិបាលកម្ពុជាដោយមិនមានការដំឡើងអត្រាពន្ធ ឬបង្កើតប្រភេទពន្ធថ្មីគឺមានតែពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីអំពីពន្ធដារជាធរមានតែប៉ុណ្ណោះ។ គួរបញ្ជាក់ដែលថា រាជរដ្ឋាភិបាលតែងតែមានការលើកទឹកចិត្ត ចំពោះការវិនិយោគលើវិស័យកសិកម្ម វិស័យអប់រំ និងវិស័យអទិភាពនានាផ្សេងទៀត រួមទាំងសហគ្រាសធុនតូចនិងសហគ្រាសធុនមធ្យម។ គោលនយោបាយលើកទឹកចិត្តនៅតែគិតគូរដល់អាជីវកម្មតូចៗនិងប្រជាពលរដ្ឋ។អគ្គនាយកដ្ឋានពន្ធដារមានចក្ខុវិស័យច្បាស់លាស់ក្នុងការធ្វើកំណែទម្រង់តាមរយៈការអនុវត្តយុត្តិសាស្រ្តកៀរគរចំណូលរយៈពេលមធ្យមឆ្នាំ២០១៤ដល់២០១៨ រហូតឈានដល់ការអនុវត្តការគ្រប់គ្រងប្រមូលចំណូល និងសម្រេចបានលើសផែនការដែលច្បាប់បានកំណត់ ដែលផ្សារភ្ជាប់នឹងយន្តការសំខាន់ៗ ៤ ដែលបានដាក់ចេញនិងអនុវត្តន៍រួមមាន ទី១គឺការកែលម្អរដ្ឋបាលសារពើពន្ធជាពិសេសការធ្វើទំនើបកម្មព័ត៌មានវិទ្យា ទី២គឺការពង្រឹងអភិបាលកិច្ចល្អ ទី៣គឺការកែសម្អគោលនយោបាយសារពើពន្ធ និងបទប្បញ្ញត្តិផ្សេងៗ ទី៤គឺការពង្រឹងវប្បធម៌បង់ពន្ធ។ គួរបញ្ជាក់ផងដែរថាថ្មីៗនេះអគ្គនាយកដ្ឋានពន្ធដារបានដាក់ឲ្យដំណើការនូវប្រពន្ធគ្រប់គ្រងទិន្នន័យ សវនកម្មសហគ្រាសក្នុងគោលដៅពង្រឹងតម្លាភាពនៃការធ្វើសវនកម្មនឹងគ្រប់គ្រង ទិន្នន័យសហគ្រាស ហើយក៏នឹងត្រៀមដាក់ឲ្យដំណើរការនូវប្រព័ន្ធបង់ប្រាក់តាម E-PAYMENT ដែលអាចផ្តល់ភាពងាយស្រួល និងភាពប្រសើរឡើងនៃសេវាអ្នកជាប់ពន្ធដល់សហគ្រាសនានា។[20]

[20] សេចក្តីប្រកាសព័ត៌មានការធ្វើបទបង្ហាញស្តីអំពីឱកាសនៃការវិយោគនៅកម្ពុជា២០១៧

# ជំពូកទី៤
# ការវិភាគលើចំណុចខ្លាំង និងចំណុចខ្សោយ

## ៤.១ ការវិភាគលើចំណុចខ្លាំង

- ការបង្កើតប្រាក់ចំណូល៖ ពន្ធផ្តល់ឱ្យរដ្ឋាភិបាលកម្ពុជានូវប្រភពចំណូលដ៏សំខាន់ ដែលអាចប្រើប្រាស់ដើម្បីផ្តល់មូលនិធិដល់ គម្រោងហេដ្ឋារចនាសម្ព័ន្ធសាធារណៈកម្មវិធីសុខុមាលភាពសង្គម និង សេវាកម្មសំខាន់ៗ។ ការវិនិយោគលើទំនិញ និងសេវាកម្មសាធារណៈនេះអាចជំរុញកំណើនសេដ្ឋកិច្ចដោយការកែលម្អផលិតភាព ធនធានមនុស្ស និងសុខុមាលភាពទូទៅ។
- ស្ថិរភាពសារពើពន្ធ៖ ប្រព័ន្ធពន្ធដារដែលបានរចនាយ៉ាងត្រឹមត្រូវអាចរួមចំណែកដល់ស្ថិរភាពសារពើពន្ធដោយផ្តល់នូវលំហូរនៃប្រាក់ចំណូលជាប្រចាំសម្រាប់រដ្ឋាភិបាល។ ស្ថិរភាពនេះបង្កើតបរិយាកាសអំណោយផលសម្រាប់អាជីវកម្មដើម្បីធ្វើប្រតិបត្តិការ និងវិនិយោគ ជំរុញទំនុកចិត្ត និងកំណើនសេដ្ឋកិច្ចរយៈពេលវែង។
- ការបែងចែកធនធាន៖ ពន្ធអាចត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់ការបែងចែកធនធាន ជំរុញការវិនិយោគក្នុងវិស័យសំខាន់ៗ នៃសេដ្ឋកិច្ចតាមរយៈការ លើកទឹកចិត្ត និងការលើកលែងពន្ធ។ ការវិនិយោគគោលដៅនេះអាចជំរុញសកម្មភាពសេដ្ឋកិច្ច បង្កើតការងារ និងជំរុញការច្នៃប្រឌិត និងការប្រកួតប្រជែង។
- ការបែងចែកទ្រព្យសម្បត្តិឡើងវិញ៖ គោលនយោបាយពន្ធដារដែលរីកចម្រើនអាចជួយកាត់បន្ថយវិសមភាពប្រាក់ចំណូលដោយការចែកចាយទ្រព្យសម្បត្តិឡើងវិញពីបុគ្គលដែលមានប្រាក់ចំណូលខ្ពស់ និងអាជីវកម្មទៅកាន់អ្នកដែលមានប្រាក់ចំណូលទាប។ ការបែងចែកឡើងវិញនេះអាចបង្កើនភាពស្អិតរមួតក្នុងសង្គម កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សង្គមមួយដែលមានសមធម៌ជាងមុន ដែលមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។

## ៤.២ ការវិភាគលើចំណុចខ្សោយ

- ការមិនលើកទឹកចិត្តសម្រាប់ការវិនិយោគ ៖ អត្រាពន្ធខ្ពស់ ឬរចនាសម្ព័ន្ធពន្ធស្មុគស្មាញអាចដើរតួនាទីជាការមិនលើកទឹកចិត្តសម្រាប់ការវិនិយោគ សហគ្រិនភាព និងសកម្មភាពសេដ្ឋកិច្ច។ ការយកពន្ធច្រើនពេកអាចកាត់បន្ថយប្រាក់ចំណូលគ្រួសារ និងប្រាក់ចំណេញរបស់អាជីវកម្ម ដែលនាំឱ្យការវិនិយោគទាប ការបង្កើតការងារ និងកំណើនសេដ្ឋកិច្ចទាំងមូល។
- ការគេចពន្ធ និងសេដ្ឋកិច្ចក្រៅផ្លូវការ៖ យន្តការអនុវត្តពន្ធ និងអនុលោមភាពមិនត្រឹមត្រូវអាចនាំទៅរកការគេចពន្ធរីករាលដាល និងការរីកសាយនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ។ នេះធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃប្រព័ន្ធពន្ធដារ កាត់បន្ថយប្រាក់ចំណូលរបស់រដ្ឋាភិបាល និងបង្ខូចការប្រកួតប្រជែងទីផ្សារ ទីបំផុតរារាំងដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍។
- ការចំណាយលើការអនុលោមភាព៖ បន្ទុករដ្ឋបាលនៃការអនុលោមតាមពន្ធ រួមទាំងការរក្សាកំណត់ត្រា តម្រូវការដាក់ឯកសារ និងរបាយការណ៍ពន្ធ អាចជាការចំណាយ និងចំណាយពេលវេលាសម្រាប់អាជីវកម្ម ជាពិសេសសហគ្រាសធុនតូច និងមធ្យម(SMEs)។ការចំណាយលើការអនុលោមតាមច្បាប់ខ្ពស់អាចបង្វែរធនធានឱ្យឆ្ងាយពីការវិនិយោគប្រកប ដោយផលិតភាព និងការបង្កើតថ្មី ដោយធ្វើឱ្យប៉ះពាល់ដល់កំណើនសេដ្ឋកិច្ច។
- ឥទ្ធិពលបង្ខូចទ្រង់ទ្រាយ៖ ពន្ធមួយចំនួនដូចជា ពន្ធគយ ពន្ធអាករ និងពន្ធលើការលក់ អាចបង្ខូចការលើកទឹកចិត្តទីផ្សារ និងអាកប្បកិរិយារបស់អ្នកប្រើប្រាស់ ដែលនាំឱ្យខ្វះប្រសិទ្ធភាពក្នុងការបែងចែកធនធាន និងកាត់បន្ថយសុខុមាលភាពសេដ្ឋកិច្ច។

ឧទាហរណ៍ ពន្ធនាំចូលខ្ពស់អាចបង្កើនថ្លៃដើមនៃទំនិញនាំចូល កាត់បន្ថយអំណាចទិញរបស់អ្នកប្រើប្រាស់ និងកំណត់ការចូលប្រើប្រាស់ទំនិញ និងសេវាកម្មសំខាន់ៗ។

# ជំពូកទី៥
# ការសន្និដ្ឋាន និងផ្តល់អនុសាសន៍

## ៥.១ សេចក្តីសន្និដ្ឋាន

- ពន្ធគឺជាប្រភពចំណូលដ៏សំខាន់ ៖ ពន្ធដើរតួនាទីយ៉ាងសំខាន់ ក្នុងការផ្តល់មូលនិធិដល់ហេដ្ឋារចនាសម្ព័ន្ធ សាធារណៈកម្មវិធី សុខុមាលភាពសង្គម និង សេវាកម្មសំខាន់ៗនៅក្នុងប្រទេសកម្ពុជា។ ពួកគេផ្តល់ឱ្យរដ្ឋាភិបាលនូវប្រាក់ចំណូលចាំបាច់ក្នុងការវិនិយោគលើវិស័យសំខាន់ៗដែលជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍។
- ស្ថិរភាពសារពើពន្ធគឺចាំបាច់៖ ប្រព័ន្ធពន្ធដារដែលបានរចនាយ៉ាងល្អ រួមចំណែកដល់ស្ថិរភាពសារពើពន្ធ ដោយផ្តល់នូវលំហូរចំណូលជាបន្តសម្រាប់រដ្ឋាភិបាល។ ស្ថិរភាពនេះគឺចាំបាច់សម្រាប់ការបង្កើតបរិយាកាសអំណោយផលដល់ការវិនិយោគអាជីវកម្ម សកម្មភាពសេដ្ឋកិច្ច និងកំណើនរយៈពេលវែង។
- ការដោះស្រាយវិសមភាពមានសារៈសំខាន់៖ គោលនយោបាយពន្ធដារដែលរីកចម្រើនអាចជួយកាត់បន្ថយវិសមភាពប្រាក់ចំណូលដោយការចែកចាយទ្រព្យសម្បត្តិ និងធនធានឡើងវិញដល់អ្នកដែលមានប្រាក់ចំណូលទាប។ ការដោះស្រាយវិសមភាពគឺមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ភាពស្អិតរមួតក្នុងសង្គម និងធានាថាអត្ថប្រយោជន៍នៃកំណើនសេដ្ឋកិច្ចត្រូវបានចែករំលែកកាន់តែស្មើភាពគ្នានៅទូទាំងសង្គម។ តុល្យភាពនៃការលើកទឹកចិត្តនិងការចំណាយ ខណៈពេលដែលពន្ធអាចជំរុញការវិនិយោគ និងការបែងចែកធនធាន អ្នកបង្កើតគោលនយោបាយត្រូវតែមានតុល្យភាពរវាង ការផ្តល់ការលើកទឹកចិត្តសម្រាប់សកម្មភាពសេដ្ឋកិច្ចនិងកាត់បន្ថយការចំណាយ និងការបង្ខូចទ្រង់ទ្រាយដែលទាក់ទងនឹងពន្ធ។ អត្រាពន្ធខ្ពស់បន្ទុកអនុលោមភាព និងពន្ធបង្ខូចទ្រង់ទ្រាយអាចរារាំងកំណើនសេដ្ឋកិច្ច និងការប្រកួតប្រជែង។

## ៥.២ ការផ្តល់អនុសាសន៍

- សម្រួលការគ្រប់គ្រងពន្ធដារ ៖ ការសម្រួលច្បាប់ពន្ធដារ នីតិវិធី និងតម្រូវការអនុលោមភាព អាចកាត់បន្ថយបន្ទុករដ្ឋបាលសម្រាប់អាជីវកម្ម និងបុគ្គល។ នេះអាចធ្វើអោយប្រសើរឡើងនូវការអនុលោមតាមច្បាប់ពន្ធ កាត់បន្ថយការគេចវេស និងបង្កើនប្រសិទ្ធភាពនៃប្រព័ន្ធពន្ធ។
- លើកកម្ពស់គោលនយោបាយពន្ធដែលងាយស្រួលវិនិយោគ៖ ការអនុវត្តការលើកទឹកចិត្តពន្ធ និងការលើកលែងសម្រាប់វិស័យសំខាន់ៗដូចជា ផលិតកម្ម កសិកម្ម និងទេសចរណ៍ អាចជំរុញការវិនិយោគ ការបង្កើតការងារ និងការធ្វើពិពិធកម្មសេដ្ឋកិច្ច។ ទោះជាយ៉ាងណាក៏ដោយ ការលើកទឹកចិត្តទាំងនេះគួរតែត្រូវបាន កំណត់គោលដៅដោយប្រុងប្រយ័ត្ននិងវាយតម្លៃជាទៀងទាត់ ដើម្បីធានាបាននូវប្រសិទ្ធភាព និងទប់ស្កាត់ការរំលោភបំពាន។
- ពង្រឹងការអនុវត្តពន្ធដារ និងការអនុលោមតាមច្បាប់៖ ការពង្រឹងយន្តការអនុវត្តពន្ធ រួមទាំងការធ្វើសវនកម្ម ការត្រួតពិនិត្យ និងសកម្មភាពអនុវត្តអាចរារាំងការគេចពន្ធ និងបង្កើនការប្រមូលចំណូល។ ការវិនិយោគលើបច្ចេកវិទ្យា និងការកសាងសមត្ថភាពសម្រាប់អាជ្ញាធរពន្ធដារអាចបង្កើនប្រសិទ្ធភាព និងប្រសិទ្ធភាពក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តច្បាប់។
- ពិចារណាពីផលប៉ះពាល់នៃសមធម៌៖ ការវាយតម្លៃផលប៉ះពាល់នៃការចែកចាយនៃគោលនយោបាយពន្ធលើក្រុមចំណូលផ្សេងៗគ្នា និងប្រជាជនដែលងាយរងគ្រោះគឺមានសារៈសំខាន់សម្រាប់ការលើកកម្ពស់សមធម៌ និងការរួមបញ្ចូលសង្គម។ អ្នកបង្កើតគោលនយោបាយគួរតែរៀបចំប្រព័ន្ធពន្ធដារដែលមានវឌ្ឍនភាព យុត្តិធម៌ និងគាំទ្រដល់កំណើនដែលរួមបញ្ចូល។
- តាមដាននិងវាយតម្លៃគោលនយោបាយពន្ធដារ៖ ការត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនៃគោលនយោបាយពន្ធដារ និងផលប៉ះពាល់របស់វាទៅលើកំណើនសេដ្ឋកិច្ច ការប្រមូលចំណូល និងសុខុមាលភាពសង្គមគឺមានសារៈសំខាន់ សម្រាប់ការសម្រេចចិត្តលើគោលនយោបាយដែលមានព័ត៌មាន។ ការត្រួតពិនិត្យតាមកាលកំណត់អាចជួយកំណត់តំបន់សម្រាប់ការកែលម្អ និងធានាថាគោលនយោបាយពន្ធដារនៅតែស្របតាមអាទិភាពនៃការអភិវឌ្ឍន៍ជាតិ។

តាមរយៈការអនុវត្តអនុសាសន៍ទាំងនេះ និងអនុវត្តវិធីសាស្ត្រប្រកបដោយតុល្យភាពចំពោះការយកពន្ធ កម្ពុជាអាចទាញយកសក្តានុពលនៃពន្ធ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព កាត់បន្ថយវិសមភាព និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ។

# ឯកសារយោងជាភាសាខ្មែរ


1. របាយការណ៍តួលេខដែលបោះផ្សាយដោយ (WBG) កាលពីថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ២០១៦
2. របាយការណ៍បច្ចុប្បន្នភាពនៃ WORLD BANK (០៦ ឧសភា ២០១៩)
3. របាយការណ៍អគ្គនាយកដ្ឋានពន្ធដារប្រចាំខែធ្នូ ឆ្នាំ២០២០
4. ធនាគារជាតិនៃកម្ពុជា «ផែនការអភិវឌ្ឍវិស័យហិរញ្ញវត្ថុឆ្នាំ ២០១៦-២០២៥»
5. រាជរដ្ឋាភិបាលកម្ពុជា «យុទ្ធសាស្ត្រចតុកោណសម្រាប់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព៖ ការប្រជុំគណៈរដ្ឋមន្ត្រីដំបូងនៃនីតិកាលទី ៣ នៃរដ្ឋសភាជាតិនៅទីស្តីការគណៈរដ្ឋមន្ត្រី» ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១៤។
6. រាជរដ្ឋាភិបាលកម្ពុជា «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ (NSDP) ២០១៩-២០២៣» ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៩។
7. ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) «ការសិក្សាលើប្រទេសកម្ពុជាក្នុងការធ្វើពិពិធកម្មក្រៅពីវិស័យសម្លៀកបំពាក់ និងទេសចរណ៍» ខែវិច្ឆិកា ឆ្នាំ ២០១៤។
8. រាជរដ្ឋាភិបាលកម្ពុជា «យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាលកម្ពុជា» ខែកញ្ញា ឆ្នាំ ២០១៨។
9. អគ្គនាយកដ្ឋានពន្ធដារ
10. https://www.khsearch.com/qna/27813
11. មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) «គោលនយោបាយសារពើពន្ធ៖ ការប្រមូលចំណូល និងការចំណាយ» ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០២០។
12. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ «របាយការណ៍នៃការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជាឆ្នាំ ២០១៥ ដោយផ្អែកលើវិធីសាស្ត្រចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ» ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥។
13. ធនាគារពិភពលោក (WB) «ការកែលម្អប្រសិទ្ធភាពនៃហិរញ្ញវត្ថុសាធារណៈ៖ ការពិនិត្យឡើងវិញការចំណាយសាធារណៈនៅកម្ពុជា» ខែមិថុនា ឆ្នាំ២០១៩។
14. ធនាគារពិភពលោក (WB)
15. រឿងភូមិតិរច្ឆាន(១៩៦៤-១៩៦៥)
16. ការអនុវត្តថវិកាជាតិ(២០១០-២០២០)
17. ការអនុវត្តថវិការដ្ឋឆ្នាំ២០១០ ដល់ ២០២០

18. រាជរដ្ឋាភិបាលកម្ពុជា «គណៈកម្មាធិការដឹកនាំនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ សេចក្តីព្រាងចុងក្រោយនៃរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ ២០១៨» ឆ្នាំ២០១៨។
19. សៀវភៅលោកគ្រូ ដួងកណ្ណារ៉ា(២០១៨-២០១៩)
20. សេចក្តីប្រកាសព័ត៌មានការធ្វើបទបង្ហាញស្តីអំពីឱកាសនៃការវិនិយោគនៅកម្ពុជា២០១៧
21. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គោលនយោបាយ និងការគ្រប់គ្រងសេដ្ឋកិច្ច | Open Development Cambodia (ODC)

# ឯកសារយោងជាភាសាបទេស


1. Ghozali, I. (2006). Aplikasi Analisis Multivariate dengan Program SPSS. BadanPenerbit Universitas Diponegoro, Semarang.
2. Jim (2018), Skewness and Kurtosis: 2 Important Statistics terms in Data Science. Retrieved
3. Algifari(2000),Analisis Regresi: Teori, Kasus dan Solusi, Edisi Kedua, BPFYogyakarta
4. Jim (2018), Skewness and Kurtosis: 2 Important Statistics terms in Data Science.Retrievedfrom:https://codeburst.io/2-important-statistics-terms-you-need-to- Retrieved from: https://codeburst.io/2-important-statistics-terms-you-need-to-
5. Saunders & Lewis (2000), Research Methods for Business Student, SecondEdition, Prentice Hall
6. Usman, Bahtiar, 2003, “Analisis Rasio Keuangan dalam Memprediksi PerubahanLabapada Bank- Bank di Indonesia”, Media Riset Bisnis & Manajemen,
7. Mary, Martin, Mercy, Stephen Ibiunni &Adebola Adetoyinbo (២០១៧)/ Bells University Of Technology , Nottingham Trent University ,Covenant University Ota ogum State https://www.researchgate.net/publication/323485389
8. KARUMBA APOLLO KAIFRANYA (២០១៦) Economic Policy Management of the University of Nairobi, Kenya
9. Hieu Huu NGUYEN (២០១៩)/ Journal of Asian Finance, Economic and business vol6 No 4, 129-137
10. SUNA KORKMAZ, METHEHAN YILGOR, FARSIME AKSOY(២០១៩) Bandirma onyedi Eylul University, Department of Economic, 10200 .

# ឧបសម្ព័ន្ធ

- តារាងសង្ខេបចំណូលពន្ធដារឆ្នាំ២០១០ដល់២០២០ចំណូលពន្ធ( គិតជាប៊ីលានរៀល )

| ឆ្នាំ/ត្រីមាស | ពន្ធផ្ទាល់ | ពន្ធប្រយោល | ពន្ធពាណិជ្ជកម្មក្រៅប្រទេស |
|---|---|---|---|
| 2020 | 5760.31 | 11244.02 | 21209.84 |
| 1 | 910 | 3166.60 | 5539.68 |
| 2 | 2409.41 | 2378.40 | 5589.68 |
| 3 | 944.9 | 2449.02 | 4190.44 |
| 4 | 1496 | 3250.00 | 5890.04 |
| 2019 | 3887.18 | 13812.62 | 24749.48 |
| 1 | 1003.35 | 2901.48 | 5097.49 |
| 2 | 612.13 | 3332.80 | 6357.14 |
| 3 | 907.8 | 3726.32 | 6364.51 |
| 4 | 1363.9 | 3852.02 | 6930.34 |
| 2018 | 3886.99 | 10761.39 | 19743.14 |
| 1 | 978.81 | 2491 | 4357.64 |
| 2 | 1279.6 | 2570.8 | 5080.62 |
| 3 | 803.74 | 2621.19 | 4670.25 |
| 4 | 824.84 | 3078.40 | 5634.63 |
| 2017 | 3764.42 | 7678.14 | 16648.26 |
| 1 | 1278.83 | 1280.07 | 4310.46 |
| 2 | 1136 | 1971.6 | 4093.53 |
| 3 | 727.35 | 2120.27 | 3922.55 |
| 4 | 622.24 | 2306.2 | 4321.72 |
| 2016 | 2952.48 | 7233.38 | 14202.05 |
| 1 | 897.25 | 1818.09 | 3533.09 |

| | | | |
|---|---|---|---|
| 2 | 982.05 | 1872.49 | 3849.68 |
| 3 | 577.74 | 1800.8 | 3414.28 |
| 4 | 495.44 | 1742 | 3405 |
| 2015 | 2646.71 | 3554.24 | 11879.93 |
| 1 | 598.71 | 838 | 2647.8 |
| 2 | 900.9 | 853.82 | 3301.56 |
| 3 | 490.8 | 1000.94 | 3063.27 |
| 4 | 656.3 | 861.48 | 2867.3 |
| 2014 | 1479.14 | 2990.93 | 10603.21 |
| 1 | 291.7 | 729.16 | 2220.49 |
| 2 | 632.82 | 465.35 | 2838.66 |
| 3 | 291.43 | 859.09 | 2595.43 |
| 4 | 263.19 | 937.33 | 2948.63 |
| 2013 | 1184.06 | 2705.56 | 8773.77 |
| 1 | 248.42 | 554.64 | 1823.61 |
| 2 | 511.11 | 635.8 | 2252.85 |
| 3 | 194.6 | 674.9 | 1868.85 |
| 4 | 229.93 | 840.22 | 2828.46 |
| 2012 | 976.86 | 2399.62 | 8143.54 |
| 1 | 199.6 | 470.72 | 1728.95 |
| 2 | 389.01 | 575.43 | 2045.07 |
| 3 | 207.16 | 608.09 | 1900.8 |
| 4 | 181.09 | 745.38 | 2468.72 |
| 2011 | 723.87 | 1943.05 | 6444.81 |
| 1 | 169.64 | 385.37 | 1407.19 |
| 2 | 261.03 | 444.09 | 1519.47 |

| | | | |
|---|---|---|---|
| 3 | 139.9 | 497.47 | 1510.12 |
| 4 | 153.3 | 616.12 | 2008.03 |
| 2010 | 602.65 | 1672.5 | 5868.69 |
| 1 | 155.8 | 374.1 | 1424.61 |
| 2 | 182.45 | 403.9 | 1341.1 |
| 3 | 147.12 | 461.8 | 1427.95 |
| 4 | 117.28 | 432.7 | 1675.03 |

- តារាងតម្លៃនៃGDP ចាប់ពីឆ្នាំ២០១០ដល់២០២០(គិតជាប៊ីលានរៀល)

| ឆ្នាំ | ចំណាយចរន្ត | ចំណាមូលធន |
|---|---|---|
| 2020 | 16685.12 | 8811.87 |
| 2019 | 15239.43 | 6971.79 |
| 2018 | 13296.95 | 5730.14 |
| 2017 | 12043.72 | 5207.28 |
| 2016 | 99990.09 | 3785.3 |
| 2015 | 8544.57 | 5290.34 |
| 2014 | 7715.8 | 5590.72 |
| 2013 | 7310.01 | 5568.07 |
| 2012 | 6677.33 | 5229.7 |
| 2011 | 5784.31 | 4746.37 |
| 2010 | 4792.33 | 4436.58 |

- តារាងសង្ខេបចំណាយរបស់រដ្ឋាភិបាលឆ្នាំ២០១០ដល់២០២០(គិតជាប៊ីលានរៀល)

| ឆ្នាំ | ចំណាយចរន្ត | ចំណាមូលធន |
|---|---|---|
| 2020 | 16685.12 | 8811.87 |
| 2019 | 15239.43 | 6971.79 |
| 2018 | 13296.95 | 5730.14 |
| 2017 | 12043.72 | 5207.28 |
| 2016 | 99990.09 | 3785.3 |
| 2015 | 8544.57 | 5290.34 |
| 2014 | 7715.8 | 5590.72 |
| 2013 | 7310.01 | 5568.07 |
| 2012 | 6677.33 | 5229.7 |
| 2011 | 5784.31 | 4746.37 |
| 2010 | 4792.33 | 4436.58 |